វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីការកែប្រែប្រសើរឡើង
Working Together for Positive Change

ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

# គំនូសផែនទី

# នៃ

# ព័ត៌មានស្តីពីថវិកានៅក្នុងវិស័យអប់រំ


រាជធានីភ្នំពេញ កម្ពុជា

ខែមេសា ឆ្នាំ២០០៩

# គំនូសផែនទីនៃព័ត៌មានស្ដីពីថវិកានៅក្នុងវិស័យអប់រំ

គម្រោងថវិកាជាតិរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា បានប្រគល់ការងារសិក្សាស្រាវជ្រាវនេះជូនលោក **ប៉ក់ គឹមជឿន** ដោយបានសហការជាមួយអង្គការភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកស្ទួយតម្លាភាពថវិកា។

**សេចក្ដីបញ្ជាក់:** ទស្សនៈសម្ដែងនៅក្នុងរបាយការណ៍នេះ ជាទស្សនៈរបស់អ្នកស្រាវជ្រាវ និងមិនតំណាងឱ្យ ទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា ឬអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលទេ។ ខ្លឹមសារនៃរបាយការណ៍នេះអាចដកស្រង់ និងបោះពុម្ពឡើងវិញបាន ដោយមានការទទួលស្គាល់ និងការអនុញ្ញាតពីអ្នកស្រាវជ្រាវនិងស្ថាប័នបោះពុម្ពផ្សាយតាមការចាំបាច់។

© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា ខែមេសា ឆ្នាំ២០០៩

# មាតិកា


**បញ្ជីពាក្យកាត់** i

**សេចក្តីថ្លែងអំណរគុណ** iii

**សេចក្តីសង្ខេប** iv

**១. សេចក្តីផ្តើម** ១

**២. សាវតារ** ១

**៣. តើការសិក្សានេះនឹងវាយតម្លៃព័ត៌មានអ្វីខ្លះ?** ៣

**៤. វិធីសាស្ត្រ និងរចនាសម្ព័ន្ធនៃរបាយការណ៍** ៤

**៥. ទស្សនៈរួមអំពីវិស័យ: គោលនយោបាយ និងចំណាត់ការហិរញ្ញប្បទាន** ៥

៥.១ គោលនយោបាយអប់រំ ៥

៥.២ ការធ្វើផែនការ និងហិរញ្ញប្បទានក្នុងវិស័យអប់រំ ៧

៥.៣ រចនាសម្ព័ន្ធនៃការផ្តល់សេវា និងលំហូរមូលនិធិ ១១

៥.៤ យន្តការសម្របសម្រួលនិងសុខុដុមនីយកម្មរាជរដ្ឋាភិបាល ម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាល ១២

**៦. ព័ត៌មានថវិកា និងការចេញផ្សាយព័ត៌មាននេះនៅកម្រិតផ្សេងៗគ្នា** ១៣

៦.១ ថ្នាក់ជាតិ ១៤

៦.២ ថ្នាក់ខេត្ត និងស្រុក: ថវិកាជាតិ និងការជួយគាំទ្ររបស់ម្ចាស់ជំនួយ/អង្គការមិនមែនរដ្ឋាភិបាល ២០

៦.៣ កម្រិតសាលារៀន និងសហគមន៍ ២៥

**៧. ការផ្លាស់ប្តូរគោលនយោបាយនាពេលខាងមុខ** ២៦

៧.១ កំណែទម្រង់ក្នុងវិស័យអប់រំ ២៦

៧.២ កំណែទម្រង់ទូទាំងរាជរដ្ឋាភិបាល ២៨

**៨. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ៣០

៨.១ សម្រាប់រយៈពេលខ្លី ៣០

៨.២ សម្រាប់រយៈពេលមធ្យម និងវែង ៣១

ឧបសម្ព័ន្ធទី ១: លំហូរព័ត៌មាន និងឯកសារដែលផលិតតាមកម្រិត និងស្ថាប័នផ្សេងៗគ្នា ៣៣

ឧបសម្ព័ន្ធទី ២: ឯកសារសំខាន់ៗផលិតនៅថ្នាក់ជាតិ និងការចេញផ្សាយឯកសារទាំងនេះ ៣៤

ឧបសម្ព័ន្ធទី ៣: ឯកសារថវិកាសំខាន់ៗដែលផលិតនៅថ្នាក់ក្រោមជាតិ និងការចេញផ្សាយឯកសារទាំងនេះ ៣៧

# បញ្ជីពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយ |
| AOP | ផែនការប្រតិបត្តិការប្រចាំឆ្នាំ |
| API | វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ |
| BMC | មជ្ឈមណ្ឌលគ្រប់គ្រងថវិកា |
| CAR | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDCF | វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| COA | ប្លង់គណនី |
| CSOs | អង្គការសង្គមស៊ីវិល |
| D&D | វិមជ្ឈការ និងសហវិមជ្ឈការ |
| DEF | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| DIP | កម្មវិធីបញ្ហាអភិវឌ្ឍន៍ |
| DoEYS | មន្ទីរអប់រំ យុវជន និងកីឡា |
| EC | គណៈកម្មការអឺរ៉ុប |
| EFA | អប់រំសម្រាប់ទាំងអស់គ្នា |
| EFAC | គណៈកម្មាធិការស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា |
| EMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| ESP | គោលនយោបាយវិស័យអប់រំ |
| ESSP | កម្មវិធីទ្រទ្រង់វិស័យអប់រំ |
| ESWG | ក្រុមការងារវិស័យអប់រំ |
| FMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ |
| HRMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស |
| IBP | គម្រោងថវិកាអន្តរជាតិ |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |

| | |
|---|---|
| JTWG-Ed | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីអប់រំ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoI | ក្រសួងមហាផ្ទៃ |
| MoP | ក្រសួងផែនការ |
| MTEF | ក្របខណ្ឌចំណាយរយៈពេលមធ្យម |
| NA | រដ្ឋសភាជាតិ |
| NAA | អាជ្ញាធរសវនកម្មជាតិ |
| NEP | ភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| O&M | ការត្រួតពិនិត្យ និងការថែទាំ |
| ODA | ជំនួយអភិវឌ្ឍន៍អន្តរជាតិ |
| PAP | កម្មវិធីសកម្មភាពជាអាទិភាព |
| PBB | ថវិកាតាមកម្មវិធី |
| PETS | ការស្ទង់មតិតាមដានចំណាយសាធារណៈ |
| PFMRP | កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PIP | កម្មវិធីវិនិយោគសាធារណៈ |
| PMU | អង្គភាពគ្រប់គ្រងគម្រោង |
| R&D | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SSC | គណៈកម្មាធិការទ្រទ្រង់សាលារៀន |
| SWAp | អភិក្រមទូទាំងវិស័យ |
| SWPAM | តារាងសកម្មភាពទូទាំងវិស័យ |
| TOFE | តារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ |
| UNICEF | មូលនិធិគាំពារកុមារសហប្រជាជាតិ |
| VSO | អង្គការសេវាស្ម័គ្រចិត្តបរទេស |
| WVC | អង្គការទស្សនៈពិភពលោកកម្ពុជា |

# សេចក្តីថ្លែងអំណរគុណ

អ្នកស្រាវជ្រាវ សូមថ្លែងអំណរគុណដល់ការផ្តល់ធាតុចូលដ៏មានតម្លៃពីក្រសួងអប់រំ យុវជន និងកីឡា មន្ទីរស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសាមីពាក់ព័ន្ធដទៃទៀត។ អ្នកស្រាវជ្រាវ សូមថ្លែងអំណរគុណជាបន្តដល់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ចំពោះការត្រួតពិនិត្យ និងការផ្តល់មតិយោបល់ដ៏មានសារៈសំខាន់។ ការសិក្សាស្រាវជ្រាវនេះ នឹងមិនអាចចេញផ្សាយទៅបាននោះទេ បើគ្មានការគាំទ្រផ្នែកហិរញ្ញវត្ថុពីម្ចាស់ជំនួយ និងដៃគូ របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។

# សេចក្ដីសង្ខេប

**១.** កិច្ចការគូសផែនទីនៃព័ត៌មានស្ដីពីថវិកានៅក្នុងវិស័យអប់រំបានចាប់ផ្ដើមពី ខែធ្នូ ឆ្នាំ២០០៨ ដល់ ខែ កុម្ភៈ ឆ្នាំ២០០៩។ ការសិក្សានេះបានបង្ហាញយ៉ាងល្អិតល្អន់នូវរាល់ឯកសារ ដែលចេញផ្សាយជាសាធារណៈ ទាក់ទងនឹងការធ្វើផែនការ និងការធ្វើថវិកានៅក្នុងវិស័យអប់រំ។ គេរំពឹងថា របកគំហើញនៃការសិក្សានេះអាចជួយឱ្យអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើវិស័យអប់រំ អាចស្វែងយល់បានកាន់តែច្រើនអំពីដំណើរការនៃការធ្វើផែនការ និងការធ្វើថវិកា។ ជាប្រយោជន៍ត្រលប់មកវិញ អង្គការមិនមែនរដ្ឋាភិបាលអាចធានាបានថា កម្មវិធីរបស់ពួកគាត់អាចជួយបំពេញដល់ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល។

**២.** ការសិក្សានេះវាយតម្លៃលើ (i) ព័ត៌មានថវិកា ឬឯកសារចេញផ្សាយតាមរយៈនីតិវិធីកំណត់មួយ ដែលអាចធានាការចេញផ្សាយឯកសារសាធារណៈក្នុងពេលដូចគ្នា ទៅដល់ភាគីពាក់ព័ន្ធ និង (ii) ឯកសារ ដែលអាចទទួលបានក្នុងលក្ខខណ្ឌមានសំណូមពរ និងការយល់ព្រមជាផ្លូវការពីមន្ត្រីពាក់ព័ន្ធ។

**៣.** ការសិក្សានេះរកឃើញថា ព័ត៌មានថវិកាប្រភេទខ្លះត្រូវបានចេញផ្សាយជាសាធារណៈ ហើយព័ត៌មានប្រភេទខ្លះទៀតអាចចេញផ្សាយជាសាធារណៈទៅបាន លុះណាមានការអនុញ្ញាតពីថ្នាក់លើ រួមមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំយុវជន និងកីឡា រឺក៏តាមរយៈក្រុមការងារបច្ចេកទេសចម្រុះលើការអប់រំ។ តារាងភ្ជាប់មក បានចង្អុលបង្ហាញពីចំនុចស្ដីពីលំហូរនៃការចេញផ្សាយព័ត៌មានថវិកា។ ការស្វែងយល់អំពីការរៀបចំហិរញ្ញប្បទាននិងការផ្ដល់សេវាកម្មលើវិស័យ គឺជាប្រការមួយដ៏សំខាន់ ហើយប្រការសំខាន់មួយទៀតនោះគឺការជូនព័ត៌មានអំពីបច្ចុប្បន្នភាពនៃការផ្ដួចផ្ដើមធ្វើកំណែទំរង់ថវិកាលើវិស័យ និងប្រព័ន្ធរដ្ឋបាលទូទៅ។

**៤.** ឯកសារ និងព័ត៌មានគោលជាច្រើន ត្រូវបានបង្ហាញជាជំនួយដល់ការស្វែងយល់ពីគោលនយោបាយតាមវិស័យ ការធ្វើផែនការ និងការធ្វើថវិកា។ ឯកសារ និងព័ត៌មានទាំងនោះរួមមានៈ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDG) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) កម្មវិធីវិនិយោគសាធារណៈ (PIP) កម្មវិធីអប់រំដើម្បីទាំងអស់គ្នា (EFA) និងគោលនយោបាយវិស័យអប់រំ។ ឯកសារលម្អិតប្រចាំឆ្នាំរួមមាន ស្ថិតិ និងសូចនាករណ៍នៃការអប់រំថ្នាក់ជាតិ និងរបាយការណ៍សន្និបាតស្ដីពីការអប់រំ។

**៥.** ចំពោះការធ្វើការលើសេវាកម្មសង្គម និងការរៀបចំហិរញ្ញប្បទាន វិស័យអប់រំបច្ចុប្បន្នទទួលបានហិរញ្ញប្បទានពីថវិកាជាតិ និងការគាំទ្រពីម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល។ ជាទូទៅ គេបានចំណាយថវិកាជាតិចំពោះការចំណាយលើបុគ្គលិកនិងរដ្ឋបាល ខណៈដែលការគាំទ្រពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានផ្ដល់ឱ្យដោយផ្អែកក្នុងទម្រង់ជាគម្រោង និងជាឧបត្ថម្ភធនដល់រដ្ឋាភិបាល។ ហិរញ្ញប្បទាន ដែលអាចទទួលបាន មានលំហូរពីថ្នាក់កណ្ដាល ទៅថ្នាក់ខេត្ត ទៅថ្នាក់ស្រុក និងកម្រិតសាលារៀន[1]។ លំហូរហិរញ្ញប្ប

[1] សូមពិនិត្យមើលដ្យាក្រាមនៅទំព័រទី១១ ក្នុងរបាយការណ៍។

ទានទាំងនេះ ទាមទារឱ្យមានការស្វែងយល់ឱ្យបានច្បាស់ដើម្បីតាមដានព័ត៌មានថវិកាដែលពាក់ព័ន្ធ និងរកវិធីសាស្ត្រ ស្វែងយល់ពីព័ត៌មានទាំងនោះ ។

**៦.** មាត្រា៨៤ នៃច្បាប់ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ បានចែងថា "របាយការណ៍ហិរញ្ញវត្ថុ និងគណនេយ្យទាំងអស់ត្រូវមានតម្លាភាព និងត្រូវផ្សព្វផ្សាយជាសាធារណៈ" ។ តាមការអនុវត្ត គេសង្កេតឃើញពីបញ្ហាប្រឈមដែលមានការកម្រិតមួយចំនួនចំពោះការទទួលបានព័ត៌មានថវិកាក្នុងវិស័យអប់រំ ។ បញ្ហាប្រឈមទី១ ចេញមកពីការបែងចែករវាងថវិកាជាតិ និង ការគាំទ្រពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ។ គេសង្កេតឃើញពីបញ្ហាប្រឈម សូម្បីតែការទទួលបានព័ត៌មានពីថវិកាជាតិ និង ការគាំទ្រពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ។

**៧.** ចំពោះថវិកាជាតិ បញ្ហាប្រឈមចេញមកពីការធ្វើមជ្ឈការលើព័ត៌មានថវិកា នៅឯក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ហើយអាចចេញមកពីការបែងចែករវាងថវិកាចរន្ត និងថវិកាមូលធន ។ ចំពោះការគាំទ្រពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល គេសង្កេតឃើញមានការបែងចែកច្រើន ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ក្រសួងផែនការ(MoP) និងក្រសួងអប់រំ យុវជន និងកីឡា គឺជាភ្នាក់ងាររដ្ឋាភិបាល ដែលធ្វើការសម្របសម្រួលការគាំទ្រពីម្ចាស់ជំនួយ ។

**៨.** ទោះបីជាមានការសម្របសម្រួលនាពេលបច្ចុប្បន្ន ការបែងចែកនៅតែមានបន្ត ។ មូលដ្ឋានទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភាពល្អប្រសើរ ហើយនៅត្រូវការការកែលម្អរជាបន្តទៀត ដើម្បីឱ្យមានព័ត៌មានពេញលេញល្អ និងវឌ្ឍនភាពព័ត៌មាន ។ មូលដ្ឋានទិន្នន័យជំនួយរបស់នាយកដ្ឋានផែនការនៃក្រសួងផែនការ ជួបប្រទះនឹងបញ្ហាប្រឈមស្រដៀងគ្នានេះដែរ ដែលទាមទារឱ្យមានការសហការបន្ថែមទៀតពីដៃគូរអភិវឌ្ឍដើម្បីផ្ដល់ព័ត៌មាន និងបំពេញព័ត៌មានឱ្យទាន់ពេលវេលាស្ដីពីការឧបត្ថម្ភគាំទ្ររបស់ខ្លួននៅតាមវិស័យ ។

**៩.** មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា និងសាលារៀន បានបង្កើតជាខ្សែបញ្ជរស្ថិតក្រោមក្រសួងអប់រំ យុវជន និងកីឡា។ មន្ទីរអប់រំ យុវជន និងកីឡាមានកាតព្វកិច្ចចងក្រងសូចនាករណ៍វិស័យអប់រំ និងព័ត៌មានថវិកា ពីកម្រិតសាលារៀន និងពីកម្រិតការិយាល័យ អប់រំ យុវជន និងកីឡា ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ ដាក់ជូនទៅក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តាមរយៈឋានានុក្រមវិស័យជាខ្សែបណ្ដោយ ព័ត៌មានថវិកានៅកម្រិតថ្នាក់ក្រោមជាតិ អាចទទួលបាន លុះណាមានការអនុញ្ញាតត្រឹមត្រូវពីក្រសួងអប់រំ យុវជន និងកីឡា និង/ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**១០.** ដំណើរការ និងការចេញផ្សាយព័ត៌មានថវិកាក្នុងវិស័យអប់រំ តែងមានការផ្លាស់ប្ដូរ ដើម្បីរំលេចពីការធ្វើកំណែទម្រង់ជាបន្តបន្ទាប់នៅក្នុងវិស័យ និងកំណែទំរង់ជាអន្តរវិស័យ ។ នៅក្នុងវិស័យ ការវិវឌ្ឍន៍នៃការធ្វើថវិកាតាមកម្មវិធី (PBB) ផែនការប្រតិបត្តិការប្រចាំឆ្នាំ (AOP) ភាពល្អប្រសើរនៃការគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ

(FMIS) និងភាពល្អប្រសើរនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានជំនួយ និងផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ននៃការចេញផ្សាយព័ត៌មានថវិកា។

**១១.** កំណែទម្រង់អន្តរវិស័យដែលពាក់ព័ន្ធ រួមមានកម្មវិធីកំណែទម្រង់ជាបន្តបន្ទាប់លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) និងវិមជ្ឈការ និងវិសហមជ្ឈការ (D&D) ។ ចំពោះកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការណែនាំអំពីប្លង់គណនេយ្យថ្មី ការកែលម្អឱ្យមានភាពគ្រប់ជ្រុងជ្រោយនិងការរាយការណ៍ពីថវិកាជាតិ និងមូលដ្ឋានទិន្នន័យជំនួយប្រកបដោយភាពពេញលេញ គឺជាការសម្រួលដល់ការទទួលបានព័ត៌មានថវិកាឱ្យមានភាពងាយស្រួលឡើង ពោលគឺថវិកាជាតិ ថវិការបស់ម្ចាស់ជំនួយ និងថវិការបស់អង្គការមិនមែនរដ្ឋាភិបាល។

**១២.** វិមជ្ឈការ និងវិសហមជ្ឈការ នឹងអាចផ្លាស់ប្តូរដល់ការផ្តល់សេវាអប់រំ ការផ្តល់ហិរញ្ញប្បទានដល់សេវាអប់រំ និងការចេញផ្សាយព័ត៌មានថវិកា។ តាមរយៈកំណែទម្រង់ គេបានបង្កើតក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខេត្ត ដែលបំពេញតួនាទីជាអ្នកតំណាងឱ្យរដ្ឋបាលតាមកម្រិតនៃក្រុមប្រឹក្សានីមួយៗ។ គេរំពឹងថា ក្រុមប្រឹក្សាអាចបំពេញតួនាទីបានយ៉ាងសកម្ម ហើយពួកគេនឹងដើរតួជាមជ្ឈមណ្ឌលទំនាក់ទំនងសម្រាប់អង្គការមិនមែនរដ្ឋាភិបាល នៅពេលមានការស្នើសុំព័ត៌មានថវិកា ពីមន្ទីរសាមីតាមវិស័យ រួមទាំងវិស័យអប់រំ។ លក្ខណៈនេះ ជួយសម្រួលច្រើនដល់ការទទួលបានព័ត៌មានថវិកា ជាងការស្នើសុំតាមរយៈឋានានុក្រមក្រសួង។ គេរំពឹងថា ក្រុមប្រឹក្សាអាចធ្វើការតាមដាន និងសម្របសម្រួលកាន់តែប្រសើរឡើងជាមួយនឹងគម្រោងរបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។

**១៣.** តាមរយៈកំនែទម្រង់ លទ្ធភាពទទួលបានព័ត៌មានថវិកាក្នុងវិស័យអប់រំនឹងមានភាពល្អប្រសើរឡើង។ អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារនិងចាប់អារម្មណ៍លើបញ្ហានេះ គួរបន្តពង្រឹងយន្តការ ដែលមានស្រាប់ (JTWG-ED) ហើយព្យាយាមស្វែងរកឱកាសថ្មីបន្តទៀត ដែលអាចកើតចេញពីលទ្ធផលនៃកំណែទម្រង់ ជាបន្តបន្ទាប់ទាំងនេះ។

# គំនូសផែនទីនៃព័ត៌មានស្តីពីថវិកានៅក្នុងវិស័យអប់រំ

## ១. សេចក្តីផ្តើម

ការសិក្សានេះមានគោលបំណងវាយតម្លៃពីការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ (ថវិកា) និងព័ត៌មានមិនមែនហិរញ្ញវត្ថុ (លទ្ធផលនៃចំណាយ) នៅក្នុងវិស័យអប់រំនៅកម្ពុជានៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន។

## ២. សាវតារ

ការសិក្សានេះ គឺជាលទ្ធផលនៃការងាររបស់កម្មវិធីបញ្ហាអភិវឌ្ឍន៍ (DIP) ស្តីពីប្រសិទ្ធភាពជំនួយ និងការផ្សារភ្ជាប់ការងាររបស់កម្មវិធីបញ្ហាអភិវឌ្ឍន៍ លើការតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ ការវិភាគថវិកាជាតិ ការស្រាវជ្រាវសម្រាប់សន្ទស្សន៍ថវិកាបើកទូលាយ[២] និងការបោះពុម្ពផ្សាយនាពេលថ្មីៗរបស់កម្មវិធីបញ្ហាអភិវឌ្ឍន៍ នូវសៀវភៅណែនាំស្តីពីថវិកាជាតិ។ ការសិក្សានេះត្រូវបានធ្វើឡើងដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនឹង ការស្រាវជ្រាវ "លទ្ធភាពទទួលព័ត៌មានស្តីពីថវិកានៅក្នុងវិស័យសុខាភិបាល" ដែលត្រូវបានធ្វើឡើងដោយគម្រោងថវិកានៃកម្មវិធីបញ្ហាអភិវឌ្ឍន៍។

ការសិក្សានេះសំដៅកំណត់ទស្សនៈរួមពេញលេញមួយអំពី ***ឯកសារទាំងអស់ដែលមានជាសាធារណៈ*** ទាក់ទិននឹងការធ្វើផែនការ និងការធ្វើថវិកានៅក្នុងវិស័យអប់រំ ដូចជាឯកសារស្តីពី ១) ផែនការយុទ្ធសាស្ត្រអប់រំ, ២) កម្មវិធីទ្រទ្រង់វិស័យអប់រំ, ៣) ថវិកា, ៤) ឯកសារអនុវត្តថវិកា, ៥) របាយការណ៍ការងារវិស័យអប់រំ និង ៦) ស្ថិតិអប់រំ។ ការសិក្សានេះសំដៅបំភ្លឺ ថាតើព័ត៌មានអ្វីខ្លះត្រូវបានដាក់បញ្ចូលក្នុងឯកសារទាំងនោះ នៅទីណាដែលឯកសារទាំងនោះអាចរកបាន និងថាតើឯកសារទាំងនោះត្រូវបានផ្សព្វផ្សាយទៀងទាត់យ៉ាងណា។

ការសិក្សានេះនឹងជួយអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ដែលធ្វើការនៅក្នុងវិស័យអប់រំឱ្យយល់កាន់តែប្រសើរឡើងអំពីប្រព័ន្ធធ្វើផែនការនិងថវិកា នៅក្នុងវិស័យអប់រំ ហើយប្រការនេះនឹងជួយឱ្យពួកគេអាចធានាឱ្យបានប្រាកដថា កម្មវិធីរបស់ពួកគេគឺបំពេញបន្ថែមលើកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល។ ក្រៅពីអង្គការមិនមែនរដ្ឋាភិបាល ទស្សនៈរួមពេញលេញអំពីទីកន្លែង ដែលព័ត៌មានសាធារណៈស្តីពីវិស័យអប់រំអាចរកបាន ក៏នឹងមានប្រយោជន៍ផងដែរចំពោះសាធារណៈជនទូទៅ ដែលវាយតម្លៃខ្ពស់ចំពោះសារៈសំខាន់នៃការអប់រំ។ ការសិក្សានេះគឺមិនមែនផ្តោតលើការវិភាគទេ ពោលគឺផ្តោតតែលើគំនូសផែនទីនៃប្រភពព័ត៌មានសាធារណៈទាំងអស់ដែលទាក់ទិននឹងការធ្វើផែនការ ការធ្វើថវិកា និងព័ត៌មានស្ថិតិ។

---

[២] លទ្ធផលស្តីពីការបើកទូលាយសៀវភៅថវិកាកម្ពុជា នឹងត្រូវបានផ្សព្វផ្សាយក្នុងខែតុលា ឆ្នាំ ២០០៨។

ការសិក្សាអំពីការទទួលព័ត៌មានស្តីពីថវិកានៅក្នុងវិស័យអប់រំ ត្រូវបានធ្វើដោយអង្គការមួយក្រុមដែលរួមមានៈ

- **ភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ** (NEP) ដែលជាអង្គការសមាជិកភាពមួយនៃអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយសកម្មនៅក្នុងវិស័យអប់រំ ដែលមានគោលដៅដើម្បីអភិវឌ្ឍន៍យន្តការមួយដើម្បីជម្រុញការពិភាក្សានៅក្នុងចំណោមសមាជិកខ្លួន និងជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បី ធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំនៅកម្ពុជា។ ភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ គឺជាសមាជិកសកម្មមួយ នៃក្រុមការងារបច្ចេកទេសរាជរដ្ឋាភិបាលម្ចាស់ជំនួយស្តីពីវិស័យអប់រំ។
- **អង្គការសេវាស្ម័គ្រចិត្តបរទេស-កម្ពុជា** (VSO) ធ្វើការលើវិស័យអប់រំ សុខភាពបន្តពូជ និងសុខភាពកុមារ និងជីវភាពប្រកបដោយសុវត្ថិភាព (ព្រៃឈើ និង ជលផល)។ នៅក្នុងវិស័យអប់រំ អង្គការសេវាស្ម័គ្រចិត្តបរទេសផ្តោតលើខេត្តជនបទភាគច្រើន។ អង្គការសេវាស្ម័គ្រចិត្តបរទេស មានបណ្តាញភាពជាដៃគូដ៏ទូលាយមួយជាមួយរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត ដែលធ្វើការងារលើវិស័យអប់រំនៅគ្រប់កម្រិត។
- **អង្គការឃែរកម្ពុជា** គឺជាសមាជិកសកម្មមួយនៃភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ធ្វើការនៅក្នុងវិស័យអប់រំ ដែលរួមមានការផ្តល់អាហារូបករណ៍ដល់សិស្សនារីដែលជួបការលំបាក ការបង្រៀនយុវជនដែលគេមិនសូវគិតគូរដល់និងងាយរងគ្រោះ ដូចជា អ្នករកស៊ីផ្លូវភេទ និងយុវជនពីក្រុមជនជាតិដើមភាគតិចជាដើម។
- **អង្គការទស្សនៈពិភពលោកកម្ពុជា** (WVC) គឺជាសមាជិកសកម្មមួយនៃភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ អង្គការទស្សនៈពិភពលោកកម្ពុជា បានចូលរួមក្នុងការអភិវឌ្ឍសមត្ថភាពរបស់ប្រព័ន្ធអប់រំកម្ពុជាក្នុងរយៈពេល ១៣ ឆ្នាំកន្លងមកនេះ ដោយសាងសង់សាលារៀន ផ្តល់គ្រឿងបរិក្ខារ និងការបណ្តុះបណ្តាលចាំបាច់ ជាពិសេសជូនដល់សាលារៀននៅតំបន់ជនបទ។ ការចូលរួមបច្ចុប្បន្នរបស់អង្គការទស្សនៈពិភពលោកកម្ពុជា រួមមានសកម្មភាពមួយចំនួន ដូចជា សាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការទទួលការអប់រំសម្រាប់ក្រុមងាយរងគ្រោះនានា ដូចជាកុមារពិការជាដើម។
- **វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ** (API) បានបំបែកចេញពីអង្គការ PACT កម្ពុជា ក្នុងខែមករា ឆ្នាំ២០០៨ នៅពេលដែលវិទ្យាស្ថានបានចាប់ផ្តើមកម្មវិធីមួយក្នុងខែកក្កដា ឆ្នាំ២០០៣។ គោលបំណងរបស់វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ គឺសំដៅបង្កើនសេរីភាពប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជា ដោយបង្កើតការតស៊ូមតិកាន់តែមានប្រសិទ្ធភាព សម្រាប់ការឆ្លើយតបពីស្ថាប័នរាជរដ្ឋាភិបាល។

វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ សម្របសម្រួលបណ្តាញនៃអង្គការមិនមែនរដ្ឋាភិបាល ដែលកំពុងធ្វើការងារតស៊ូមតិដើម្បីសេរីភាពទទួលព័ត៌មានកាន់តែច្រើន ។

- **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា** គឺជាអង្គការសមាជិកភាពមួយនៃអង្គការមិនមែនរដ្ឋាភិបាល ចំនួនជាង ៨០ ដែលសំដៅពិភាក្សា ជជែក និងតស៊ូមតិអំពីការបារម្ភរបស់អង្គការមិនមែនរដ្ឋាភិបាលទាក់ទិននឹងការអភិវឌ្ឍកម្ពុជា។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា គឺជាសមាជិកសកម្មមួយនៃ ក្រុមការងារបច្ចេកទេសរាជរដ្ឋាភិបាលម្ចាស់ជំនួយស្តីពីកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការធ្វើផែនការ និងការកាត់បន្ថយភាពក្រីក្រ ។

## ៣. តើការសិក្សានេះនឹងវាយតម្លៃព័ត៌មានអ្វីខ្លះ?

ការសិក្សានេះពិនិត្យមើលប្រភេទព័ត៌មាន និងការចេញផ្សាយព័ត៌មានទាំងនេះនៅថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ ។ វាផ្តោតលើអ្វីដែលកើតឡើងក្នុងការអនុវត្ត ជាជាងលើអ្វីដែលមានចែងនៅក្នុងច្បាប់/បទបញ្ញត្តិ ។ និយមន័យនៃ "ការចេញផ្សាយជាសាធារណៈ" ត្រូវបានដកស្រង់មកពីគម្រោងថវិកាអន្តរជាតិ(IBP) ដែលរួមមានៈ

- ព័ត៌មានដែលមានតាមរយៈនីតិវិធីកំណត់ច្បាស់លាស់ ដោយធានាបាននូវការបញ្ចេញព្រមៗគ្នានូវឯកសារសាធារណៈជូនដល់គ្រប់ភាគីចាប់អារម្មណ៍ទាំងអស់ ក៏ដូចជា
- ព័ត៌មាន ឬឯកសារទាំងឡាយដែលផ្តល់ជូនបាន តាមតែសំណើស្នើសុំប៉ុណ្ណោះ ។

នៅប្រទេសកម្ពុជា ការផ្តល់សេវាអប់រំត្រូវបានផ្តល់ហិរញ្ញប្បទានភាគច្រើនដោយប្រភពពីថវិកាជាតិ និងប្រភពពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ។ ការសិក្សានេះនឹងពិនិត្យមើលប្រភពទាំងពីរនេះ ប៉ុន្តែផ្តោតលើថវិកាជាតិច្រើនជាង ដែលមានចំនួនជាងពាក់កណ្តាលនៃចំណាយសរុប ។ ដោយផ្តោតតែលើទិដ្ឋភាពបរិមាណនៃព័ត៌មានដែលមាន ការសិក្សានេះវាយតម្លៃភាពសមស្របសម្រាប់ការវិភាគគោលនយោបាយ ភាពពេញលេញ និងភាពទាន់ពេលវេលានៃព័ត៌មាន ។ ទិន្នន័យថវិកា គឺជាមុខងារនៃប្រព័ន្ធគ្រប់គ្រងថវិកា ដែលត្រូវបានដាក់ឱ្យដំណើរការ ហើយបានប្រែប្រួលគ្រប់ពេល និងបន្តប្រែប្រួល ដោយសារកំណែទម្រង់ផ្សេងៗ ទូទាំងរាជរដ្ឋាភិបាល និងនៅក្នុងកំណែទម្រង់តាមវិស័យ ។ ដូច្នេះការចេញផ្សាយទិន្នន័យ/ព័ត៌មានត្រូវបានវាយតម្លៃក្នុងបរិបទនេះ ។

ការសិក្សានេះ កំណត់ៈ

- ព័ត៌មានដែលមានសម្រាប់សាធារណៈជន
- ព័ត៌មានដែលត្រូវបានផ្តល់ជាទៀងទាត់ ឧទាហរណ៍ ជូនដល់សមាជិកក្រុមការងារបច្ចេកទេសនៅថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាបញ្ជាក់ថាព័ត៌មាននេះអាចចែកចាយបានជាសាធារណៈ
- ព័ត៌មាន ដែលត្រូវបានផ្តល់យ៉ាងទៀងទាត់ជូនសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងអង្គភាព (ដូចជាគណៈកម្មាធិការសាលារៀននៅក្នុងវិស័យអប់រំជាដើម) ។

## ៤. វិធីសាស្ត្រ និងរចនាសម្ព័ន្ធនៃរបាយការណ៍

ការសិក្សានេះ ប្រើវិធីសាស្ត្រនានាដូចខាងក្រោម:

- ស្រាវជ្រាវឯកសារ: ការសិក្សានេះចាប់ផ្ដើមដោយពិនិត្យមើលគោលនយោបាយតាមវិស័យ របាយការណ៍វាយតម្លៃ និងគោលនយោបាយ និងកំណែទម្រង់ទាក់ទិននឹងការផ្ដល់សេវានានា ដូចជា គោលនយោបាយ និងកំណែទម្រង់ទាក់ទិននឹងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) និង វិមជ្ឈការ និងវិសហមជ្ឈការ ។
- បទសម្ភាសន៍ជាមួយសមាជិកសំខាន់ៗនៃក្រុមអង្គការផ្ដល់ព័ត៌មាន: ការសម្ភាសន៍នេះ គឺដើម្បីទទួលបានយោបល់ពី អង្គការមិនមែនរដ្ឋាភិបាលផ្សេងៗដែលមានបទពិសោធន៍ក្នុងវិស័យទាំងនេះ និងដើម្បីធានាផងដែរថាឯកសារ និងរបាយការណ៍សំខាន់ៗមិនត្រូវបានមើលរំលង ដើម្បីបង្កើតឱ្យមានការពិនិត្យមើលនិពន្ធ ។
- បទសម្ភាសន៍ជាមួយស្ថាប័នកណ្ដាល: ស្ថាប័នកណ្ដាលទាំងនេះ រួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងមហាផ្ទៃ។ ជាកំណត់សម្គាល់ ក្រសួងមហាផ្ទៃគឺពាក់ព័ន្ធជាពិសេសនៅក្នុងបរិបទនេះដោយសារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលនឹងមានឥទ្ធិពលខ្លាំងលើវិស័យអប់រំក៏ដូចជាលទ្ធភាពទទួលបានព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានមិនមែនហិរញ្ញវត្ថុ ។
- បទសម្ភាសន៍នៅកម្រិតមូលដ្ឋានជាមួយតំណាងនៅថ្នាក់ខេត្ត និងស្រុក: អ្នកពិគ្រោះយោបល់ និងសមាជិកនៃក្រុមអង្គការផ្ដល់ព័ត៌មានបានចុះទៅកាន់ខេត្តពីរ ដើម្បីពិនិត្យមើលឯកសារផ្សេងៗស្ដីពីការគ្រប់គ្រងថវិកាដែលខេត្តបានរៀបចំ និងពិនិត្យមើលថាតើឯកសារទាំងនេះមានត្រូវបានផ្សព្វផ្សាយ ឬទេ ។

### តារាង ទី១: បញ្ជីបទសម្ភាសន៍

| ស្ថាប័ន | នាយកដ្ឋាន | កាលបរិច្ឆេទនៃកិច្ចប្រជុំ |
|---|---|---|
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | រតនាគារជាតិ | ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ |
| | នាយកដ្ឋានថវិកា | ថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ |
| | នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ |
| ក្រសួងអប់រំ យុវជន និងកីឡា | នាយកដ្ឋានហិរញ្ញវត្ថុ | ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨<br>ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ |
| | នាយកដ្ឋានផែនការ | ថ្ងៃទី២១, ២៨ ខែវិច្ឆិកា ឆ្នាំ២០០៨ |
| | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨<br>ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ |
| | ការិយាល័យអប់រំ យុវជន និង កីឡាស្រុក | ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨<br>ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ |
| | សាលារៀន | ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨<br>ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ |

ដើម្បីជាការឆ្លើយតបទៅនឹងគោលដៅនៃការសិក្សា និងដើម្បីឆ្លុះបញ្ចាំងពីប្រព័ន្ធហិរញ្ញប្បទាន និងថវិកានៅក្នុងវិស័យនេះ ទាំងនៅពេលបច្ចុប្បន្ន និងនៅពេលមានការផ្លាស់ប្តូរគោលនយោបាយខាងមុខ របាយការណ៍នេះត្រូវបានរៀបចំដូចខាងក្រោម :

- ការពិនិត្យមើលជារួមលើការរៀបចំហិរញ្ញប្បទាន និងគោលនយោបាយតាមវិស័យ: ជំពូកនេះចាប់ផ្តើមដោយផ្តល់ទស្សនៈរួមសង្ខេបមួយអំពីបរិបទគោលនយោបាយ និងចំណាត់ការហិរញ្ញប្បទាននៅក្នុងវិស័យនេះ។ ជំពូកនេះ ពិភាក្សាអំពីប្រភពហិរញ្ញប្បទានសំខាន់ៗ ប្រភេទថវិកាសម្រាប់ចំណាយសំខាន់ៗ និងលំហូរមូលនិធិពីប្រភពទាំងនេះទៅកាន់អង្គភាពចំណាយផ្សេងៗនៅថ្នាក់កណ្តាល ខេត្ត ស្រុក និងកម្រិតផ្តល់សេវាកម្ម។
- ឯកសារថវិកាដែលបានផលិត និងលទ្ធភាពរកបានឯកសារទាំងនេះ: ភ្ជាប់ទៅនឹងប្រភេទថវិកានីមួយៗ គឺមានឯកសារថវិកាផ្សេងៗ ដែលត្រូវបានរៀបចំដោយស្ថាប័នចំណាយទាំងនោះតាមកម្រិតនានា។ របាយការកំណត់និងអធិប្បាយឯកសារថវិកាសំខាន់ៗ ដែលបានផលិតនៅតាមកម្រិតនីមួយៗ ពោលគឺព័ត៌មានសំខាន់ៗអ្វីខ្លះស្តីពីថវិកា ដែលកម្រិតនីមួយៗមាន និងកម្រិតងាយស្រួលរកនៃឯកសារទាំងនេះ។
- ការចេញផ្សាយព័ត៌មានថវិកានៅក្នុងវិស័យអប់រំ-ការផ្លាស់ប្តូរដែលត្រូវបានរំពឹងទុកក្នុងរយៈពេលខ្លី និងមធ្យម: ប្រព័ន្ធថវិកា និងលទ្ធភាពចូលទៅកាន់ប្រព័ន្ធថវិកាទាំងនេះ វិវត្តជាបន្តបន្ទាប់ ដែលជាលទ្ធផលនៃកំណែទម្រង់ទាំងនៅក្នុងវិស័យ និងទាំងនៅក្នុងការធ្វើថវិកាជារួម ព្រមទាំងការរៀបចំតាមស្ថាប័ន។ របាយការនេះ បង្ហាញការផ្លាស់ប្តូរនាពេលខាងមុខនៅក្នុងគោលនយោបាយថវិកាតាមវិស័យទាំងនេះ និងកាលានុវត្តភាព រួមទាំងបញ្ហាប្រឈមទាំងឡាយ ដែលអាចកើតឡើង។
- អនុសាសន៍: អនុសាសន៍មួយចំនួនត្រូវបានផ្តល់អំពីអ្វីដែលអង្គការមិនមែនរដ្ឋាភិបាលគប្បីធ្វើនៅក្នុងការងារតស៊ូមតិរបស់ខ្លួន លើលទ្ធភាពទទួលថវិកានៅក្នុងវិស័យអប់រំសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។

## ៥. ទស្សនៈរួមអំពីវិស័យ: គោលនយោបាយ និងចំណាត់ការហិរញ្ញប្បទាន

### ៥.១ គោលនយោបាយអប់រំ

ឯកសារគោលនយោបាយដែលគ្រប់គ្រងវិស័យអប់រំ រួមមាន យុទ្ធសាស្ត្រចតុកោណ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ផែនការជាតិស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា និងគោលនយោបាយវិស័យអប់រំ។

គោលនយោបាយវិស័យអប់រំ ត្រូវបាននាំមុខជាបឋមដោយផែនការជាតិដ៏ទូលាយនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ និងយុទ្ធសាស្ត្រចតុកោណ (ឆ្នាំ២០០៤, ឆ្នាំ២០០៨)។ ស្របតាមគោលនយោបាយក្តោបរួមទាំងនេះ ផែនការជាក់លាក់ចំពោះវិស័យអប់រំត្រូវបានរៀបចំ

ឡើងរួមមានៈ [រយៈពេលវែង] ផែនការជាតិស្ដីពីការអប់រំសម្រាប់ ទាំងអស់គ្នា ឆ្នាំ២០០៣-២០១៥ និង [រយៈពេលមធ្យម] គោលនយោបាយវិស័យអប់រំ (ESP) ឆ្នាំ២០០១-២០០៥ ឆ្នាំ២០០៤-២០០៨ និងឆ្នាំ ២០០៦-២០១០។

ផ្អែកលើបទពិសោធន៍ជាមួយគោលនយោបាយវិស័យអប់រំ (ESP) ចំនួនពីរកន្លងមក គោលនយោបាយវិស័យអប់រំឆ្នាំ២០០៦-២០១០ កំណត់គោលដៅស្នូលចំនួនបីសម្រាប់វិស័យអប់រំៈ

១. ធានាឱ្យបាននូវការទទួលបានការអប់រំស្មើភាពគ្នា តាមរយៈការកសាងសាលារៀននៅជិតផ្ទះរបស់សិស្ស ការផ្ដល់ថវិកាប្រតិបត្តិការដល់សាលារៀនឱ្យបានទាន់ពេល ការផ្ដល់គ្រូប្រកបដោយលក្ខណៈសម្បត្តិឱ្យបានគ្រប់គ្រាន់ និងការសាងសង់អន្តេវាសិកដ្ឋានសម្រាប់សិស្ស ជាពិសេសសិស្សនារី។

២. កែលម្អគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ តាមរយៈការបង្កើនការផ្ដល់សម្ភារៈបង្រៀន ការសាងសង់បណ្ណាល័យ និងបន្ទប់ពិសោធន៍ ការបន្តធ្វើកំណែទម្រង់នៅក្នុងកម្មវិធីសិក្សា ការបង្កើនម៉ោងរៀន និងការផ្ដល់អាហារូបករណ៍ជូនដល់សិស្សក្រីក្រ។

៣. អភិវឌ្ឍស្ថាប័នអប់រំបន្ថែមទៀត និងកសាងសមត្ថភាពរបស់បុគ្គលិកអប់រំតាមរយៈ ការកែលម្អនីតិវិធីធ្វើការ ឧបករណ៍នីតិកម្ម និងការបណ្ដុះបណ្ដាលបច្ចេកទេសសម្រាប់មន្ត្រីអប់រំគ្រប់កម្រិតទាំងអស់។

ផែនការសកម្មភាពលម្អិត សូចនាករ និងក្របខ័ណ្ឌពេលវេលាសម្រាប់ការសម្រេចបានគោលដៅនីមួយៗនៃគោលដៅទាំងបីនេះ ត្រូវបានកំណត់នៅក្នុងតារាងសកម្មភាពទូទាំងវិស័យ (SWPAM) (ជាឧបសម្ព័ន្ធភ្ជាប់នឹងគោលនយោបាយវិស័យអប់រំ)។ ជាសង្ខេប តារាងសកម្មភាពទូទាំងវិស័យបង្ហាញថា យុទ្ធសាស្ត្រ និងសូចនាករមួយចំនួនសម្រាប់វាស់វឌ្ឍនភាព អាចដឹកនាំការអនុវត្តគោលដៅទាំងបីនេះ។ ជារួម គោលដៅទីមួយមានយុទ្ធសាស្ត្រចំនួន ១៤ និងសូចនាករពាក់ព័ន្ធចំនួន ២០ គោលដៅទីពីរមានយុទ្ធសាស្ត្រចំនួន ៨ និងសូចនាករពាក់ព័ន្ធចំនួន ២៥ និងគោលដៅទីបីមានយុទ្ធសាស្ត្រចំនួន ៧ និងសូចនាករពាក់ព័ន្ធចំនួន ១៧។

## ៥.២ ការធ្វើផែនការ និងហិរញ្ញប្បទានក្នុងវិស័យអប់រំ

កម្មវិធីទ្រទ្រង់វិស័យអប់រំ (ESSP) ឆ្នាំ ២០០៦-២០១០ តំណាងឱ្យសមិទ្ធផលមួយទៀតនៅក្នុងកំណែទម្រង់វិស័យអប់រំ។ ខណៈដែលគោលនយោបាយវិស័យអប់រំផ្តោតលើកម្មវត្ថុ និងចំណុចដៅនៃគោលនយោបាយ កម្មវិធីទ្រទ្រង់វិស័យអប់រំផ្តោតលើអាទិភាពហិរញ្ញប្បទាន និងកម្មវិធីដែលកំណត់ដោយគោលដៅទាំងនោះ។ កម្មវិធីទ្រទ្រង់វិស័យអប់រំផ្តល់នូវក្របខ័ណ្ឌកំណត់ថ្លៃ ចំណាយដែលត្រូវបំពេញដោយប្រភពទាំងអស់នៃហិរញ្ញប្បទាន រួមទាំងថវិកាជាតិ និងការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ ម្យ៉ាងទៀត ការចំណាយនឹងផ្តោតលើ (១) អាទិភាពកម្មវិធីថវិកាចរន្តចំនួន ១២ និង (២) អាទិភាពកម្មវិធីមូលធនចំនួន ២ (សូមមើលតារាងទី ២)។ សម្រាប់អាទិភាពនីមួយៗ កម្មវិធីទ្រទ្រង់វិស័យអប់រំ កំណត់ៈ គោលដៅ ចំណុចដៅសំខាន់ៗនិងសូចនាករ យុទ្ធសាស្ត្រនិងវិសាលភាព កម្មវិធីចម្បងនិងសកម្មភាព ការគ្រប់គ្រងនិងចំណាត់ការតាមដាន និងផែនការហិរញ្ញប្បទាន។

**តារាង ទី២ : អាទិភាពនានានៃកម្មវិធីទ្រទ្រង់វិស័យអប់រំ ២០០៦ - ២០១០**

| | |
|---|---|
| **អាទិភាពកម្មវិធីថវិកាចរន្ត (ក្រោមការធ្វើថវិកាតាមកម្មវិធី)** | |
| ១ | ប្រសិទ្ធភាពសេវាអប់រំ |
| ២ | ការពង្រីកការអប់រំកុមារតូច |
| ៣ | គុណភាព និងប្រសិទ្ធិភាពនៃការទទួលការអប់រំបឋមភូមិ |
| ៤ | គុណភាព និងប្រសិទ្ធិភាពនៃការទទួលការអប់រំមធ្យមសិក្សាបឋមភូមិ |
| ៥ | គុណភាព និងប្រសិទ្ធិភាពនៃការទទួលការអប់រំមធ្យមសិក្សាទុតិយភូមិ |
| ៦ | គុណភាព ប្រសិទ្ធភាព និងការទទួលបានការអប់រំស្មើភាពគ្នានៅកម្រិតឧត្តមសិក្សា |
| ៧ | អភិវឌ្ឍន៍គ្រូជាប្រចាំ |
| ៨ | ការផ្តល់សម្ភារៈបង្រៀនមូលដ្ឋានប្រកបដោយនិរន្តរភាព |
| ៩ | ការពង្រីកការអប់រំក្រៅប្រព័ន្ធ |
| ១០ | អភិវឌ្ឍន៍យុវជន និងកីឡា |
| ១១ | ការពង្រឹងប្រព័ន្ធតាមដាន |
| ១២ | កម្មវិធីអាហារូបករណ៍ថ្នាក់មធ្យមសិក្សាសម្រាប់ប្រជាជនក្រីក្រ |
| **អាទិភាពកម្មវិធីមូលធន** | |
| ១ | អភិវឌ្ឍន៍បរិក្ខាររូបវ័ន្តអប់រំ |
| ២ | អភិវឌ្ឍន៍ស្ថាប័ន និងសមត្ថភាព |

*ប្រភព: កម្មវិធីទ្រទ្រង់វិស័យអប់រំឆ្នាំ ២០០៦-២០១០*

របាយការណ៍រៀបចំកាលពីខែមីនាឆ្នាំ២០០៨ សម្រាប់ការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយវិស័យអប់រំ ឬកម្មវិធីទ្រទ្រង់វិស័យអប់រំឆ្នាំ២០០៦-២០១០ អធិប្បាយពីវឌ្ឍនភាពនៅក្នុងការឆ្លើយតបទៅនឹងអាទិភាពស្របតាមសូចនាករនីមួយៗ។ ម្យ៉ាងទៀត របាយការណ៍នេះ ផ្តល់នូវការវិភាគវឌ្ឍនភាពអន្តរខេត្ត ដែលបង្ហាញថាខេត្តឆ្ងាយដាច់ស្រយាលខ្លះ (ឧទាហរណ៍ ខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តព្រះវិហារ) បាននឹងកំពុងមានវឌ្ឍនភាពយ៉ាងយឺតក្នុងការអនុវត្តកម្មវិធីជាអាទិភាព។

ចាប់តាំងពីឆ្នាំ២០០០មក ហិរញ្ញប្បទានសម្រាប់វិស័យអប់រំបានកើនឡើងគិតតាមធម្មតាដូចមានបង្ហាញជូននៅក្នុងគំនូសបង្ហាញទី១ សម្រាប់រយៈពេល ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៨។ ជាមួយនិន្នាការដូចគ្នា គំនូសបង្ហាញទី១ ក៏បង្ហាញផងដែរថា ចំណែករបស់ខេត្តនៅក្នុងគណនីថវិកាវិស័យ គឺមានចំនួនជាងពាក់កណ្តាលដែលភាគច្រើន គឺដោយសារថ្លៃចំណាយច្រើនលើបុគ្គលិកនៅកម្រិតនោះ។

គំនូសបង្ហាញទី ១ : វិភាជន៍ថវិកាចរន្តសម្រាប់វិស័យអប់រំ
ចាប់ពីឆ្នាំ ២000 ដល់ ឆ្នាំ ២00៨




ដោយមានកំណើនជាលំដាប់ ការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលលើវិស័យអប់រំប្រទេសកម្ពុជា មានទម្រង់ផ្សេងៗគ្នា រួមទាំងការជួយគាំទ្រគម្រោង ការផ្តល់មូលនិធិដោយអង្គការមិនមែនរដ្ឋាភិបាល អាហារូបករណ៍ អំណោយហិរញ្ញវត្ថុ ប្រាក់កម្ចីគម្រោង/កម្មវិធី និងការជួយគាំទ្រថវិកាតាមគោលដៅកំណត់។ បច្ចុប្បន្ន គេឃើញមានម្ចាស់ជំនួយចំនួន ១៤ ដែលជួយគាំទ្រវិស័យនេះ ថ្វីបើមានតែធនាគារអភិវឌ្ឍន៍អាស៊ី និងគណៈកម្មការអឺរ៉ុបប៉ុណ្ណោះ ដែលផ្តល់ការជួយគាំទ្រថវិកាផ្ទាល់។ ម្ចាស់ជំនួយផ្សេងទៀតបន្តប្រើប្រាស់ជាចម្បងនូវគំរូផ្តល់ជំនួយផ្អែកលើគម្រោងតាមទម្លាប់។ រីឯអង្គការមិនមែនរដ្ឋាភិបាលចំនួនប្រហែល ១២៩ បាននឹងកំពុងជួយវិស័យអប់រំជាមួយគម្រោងចំនួនប្រហែល ២៣៩។

ប្រភពផ្សេងៗនៃហិរញ្ញប្បទានសម្រាប់វិស័យអប់រំ ត្រូវបានគ្រប់គ្រងផ្សេងៗគ្នា។ ថវិកាជាតិ (ដែលរួមមានការជួយគាំទ្រថវិកា) ត្រូវបានគ្រប់គ្រងតាមរយៈប្រព័ន្ធថវិការបស់រាជរដ្ឋាភិបាល រីឯគំរូផ្សេងៗត្រូវបានប្រើសម្រាប់ការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ និន្នាការទូទៅនៅក្នុងបណ្តាឆ្នាំកន្លងមក គឺថាចំណែកពីថវិកាជាតិត្រូវបានប្រើដើម្បីធ្វើហិរញ្ញប្បទានចំណាយចរន្ត ខណៈដែលការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលធ្វើហិរញ្ញប្បទានចំណាយមូលធន។ ប៉ុន្តែបច្ចុប្បន្ននេះ និន្នាការនេះមានការផ្លាស់ប្តូរ ដោយសារគម្រោងម្ចាស់ជំនួយផ្សេងៗក៏ធ្វើហិរញ្ញប្បទានចំណាយចរន្តផងដែរ។ យ៉ាងណាមិញនៅក្នុងច្បាប់ថវិកាជាតិ គម្រោងទាំងឡាយដែលគាំទ្រដោយម្ចាស់ជំនួយត្រូវបានចុះបញ្ជីភាគច្រើនក្រោម "ចំណាយមូលធន"។ ពាក្យ "ចំណាយមូលធន"នៅក្នុងច្បាប់ថវិកាជាតិ មានលក្ខណៈភណ្ឌច្រឡំខ្លះ ដោយសារគម្រោងនៅក្នុងបញ្ជីនេះក៏គាំទ្រផងដែរដល់ចំណាយប្រតិបត្តិការចរន្តផ្សេងៗ ដូចជាប្រាក់ខែបន្ថែម ថ្លៃអត្ថិសនី សម្ភារៈប្រើប្រាស់ក្នុងការិយាល័យ ថ្លៃចំណាយធ្វើដំណើរ ។ល។

យោងតាម*អនុក្រឹត្យលេខ ១៧០ អនក្រ* ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០០៦ ថវិកាជាតិមានសមាសភាគដូចខាងក្រោម៖

**ចំណាយចរន្ត**

- ការទិញទំនិញ (ជំពូក ៦០)៖ ជំពូកនេះរាប់បញ្ចូលមួយផ្នែកធំនៃជំពូក ១១ នៃប្លង់គណនីចាស់ ហើយមានជំពូករងចំនួន ៧ និងអនុជំពូករងចំនួន ២១។ ចំណាយចម្បងក្រោមសមាសភាគនេះ រួមមានចំណាយប្រតិបត្តិការទូទៅនិងថៃទាំគ្រឿងសង្ហារឹម និងទឹកភ្លើង។
- ការទិញសេវា (ជំពូក ៦១)៖ ជំពូកនេះរាប់បញ្ចូលមួយផ្នែកធំនៃជំពូក ១១ នៃប្លង់គណនីចាស់ ហើយមានជំពូករងចំនួន ៨ និងអនុជំពូករងចំនួន ១១។ ចំណាយចម្បងក្រោមសមាសភាគនេះ រួមមានការបណ្តុះបណ្តាល ជួសជុល ការធានារ៉ាប់រង និងមធ្យោបាយដឹកជញ្ជូន។
- សេវាផ្សេងទៀត (ជំពូក ៦២)៖ ជំពូកនេះរាប់បញ្ចូលមួយផ្នែកធំនៃជំពូក ១១ នៃប្លង់គណនីចាស់ ហើយមានជំពូករងចំនួន ៨ និងអនុជំពូករងចំនួន ១៨។ នៅក្នុងសមាសភាគនេះ មានជំពូកចំណាយសំខាន់ៗដែលរួមមាន ប្រាក់កម្រៃសម្រាប់បុគ្គលិកជាប់កិច្ចសន្យា ចំណាយ"ទទួលភ្ញៀវ" ចំណាយពិធីផ្សេងៗ និងចំណាយលើការផ្សាយតាមសារព័ត៌មាន។
- ការចំណាយលើបុគ្គលិក (ជំពូក ៦៤)៖ ជំពូកនេះរាប់បញ្ចូលមួយផ្នែកធំនៃអ្វីដែលធ្លាប់ស្ថិតនៅក្នុងជំពូក ១០ នៃប្លង់គណនីចាស់ ហើយមានជំពូករងចំនួន ៥ និងអនុជំពូករងចំនួន ៣០។ ចំណាយធំៗក្រោមសមាសភាគនេះ រួមមានប្រាក់ខែមូលដ្ឋាន ប្រាក់ឧបត្ថម្ភ កន្សោមអាទិភាព និងសង្គមកិច្ច (ឧទាហរណ៍ ប្រាក់សោធននិវត្តន៍)។

**ចំណាយមូលធន**

- វិនិយោគអរូបីយ (ជំពូក ២០) ភាគច្រើន រួមមានការស្រាវជ្រាវ និងអភិវឌ្ឍន៍។
- វិនិយោគរូបីយ (ជំពូក ២១) រួមមានសំណង់ ការជួសជុលអាគារ យានយន្ត និងទ្រព្យប្រើបានយូរផ្សេងទៀត។

ដូចករណីនៃវិស័យផ្សេងទៀតដែរ គេគប្បីកត់សម្គាល់ថា មានតែថវិកាចរន្តប៉ុណ្ណោះដែលត្រូវបានបែងចែកទៅឱ្យវិស័យអប់រំ។ ចំណាយមូលធនដែលត្រូវបានធ្វើហិរញ្ញប្បទានដោយថវិការដ្ឋ ត្រូវបានគ្រប់គ្រងក្រោមនាយកដ្ឋានវិនិយោគនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការធ្វើថវិកាចរន្ត អាចត្រូវបានចែកចេញជាការធ្វើថវិកាមិនតាមកម្មវិធី និងថវិកាតាមកម្មវិធី (PBB)។ ថវិកាតាមកម្មវិធីរាប់បញ្ចូលចំណាយចរន្តមិនមែនប្រាក់ខែ រួមមានចំណាយទាំងឡាយ ក្រោមជំពូក ៦០ ៦១ និង ៦២។ ដោយបានសិក្សាពីបទពិសោធន៍នៃកម្មវិធីសកម្មភាពជាអាទិភាព(PAP) ដែលត្រូវបានអនុវត្តពីឆ្នាំ ២០០០ ដល់ ឆ្នាំ២០០៦ ថវិកាតាមកម្មវិធីគឺជាគំនិតផ្តួចផ្តើមកំណែទម្រង់ថ្មីមួយ ក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រង

ហិរញ្ញវត្ថុសាធារណៈ(PFMRP) របស់រាជរដ្ឋាភិបាល។ ថវិកាតាមកម្មវិធីសំដៅផ្សារភ្ជាប់ចំណាយជាមួយនឹងការបំពេញការងារ។ ចំពោះវិស័យអប់រំ ថវិកាតាមកម្មវិធីត្រូវបានប្រើសម្រាប់ថ្នាក់កណ្ដាលផង និងថ្នាក់ខេត្តផង និងសម្រាប់អាទិភាពថវិកាចរន្តទាំង១២ ដែលបានលើកឡើងខាងលើក្នុងតារាងទី២។ ថវិកាតាមកម្មវិធីត្រូវបានគ្រប់គ្រងដោយមជ្ឈមណ្ឌលគ្រប់គ្រងថវិកា ដែលមាននៅគ្រប់កម្រិតទាំងអស់នៃវិស័យអប់រំ។ ថវិកាតាមកម្មវិធីភាគច្រើនគឺ ផ្អែកលើរូបមន្ត។ ថវិកាតាមកម្មវិធីគឺ ខុសគ្នាពីកម្មវិធីសកម្មភាពជាអាទិភាព ក្នុងទិដ្ឋភាពមួយចំនួន (១) វាត្រូវបានធ្វើចំណាត់ថ្នាក់ស្របតាមប្លង់គណនីថ្មី (២) វាមិនអាចដាក់បញ្ចូលទៅក្នុងឆ្នាំសារពើពន្ធបន្ទាប់បានទេ និង (៣) មានភាពបត់បែនបានតិចជាងនៅក្នុងរបៀបដែលថវិកានេះត្រូវបានគេចាយ។

**ប្រអប់ទី ១: ថវិកាតាមកម្មវិធី (PBB) នៅក្នុងវិស័យអប់រំ**[៣]

- ចាប់តាំងពីឆ្នាំ ២០០៧ មក ចំណាយនៃថវិកាតាមកម្មវិធីគឺជាការបន្តពីកម្មវិធីសកម្មភាពជាអាទិភាព។
- បទបញ្ញត្តិគន្លឹះស្ដីពីថវិកាតាមកម្មវិធីគឺប្រកាសអន្តរក្រសួងលេខ ១៩១ សហវ.ហក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០០៧ ស្ដីពីគោលការណ៍សម្រាប់អនុវត្តថវិកាតាមកម្មវិធីនៅក្នុងវិស័យអប់រំ។
- កម្មវិធីសំខាន់ៗចំនួន ៥ សម្រាប់វិស័យអប់រំ រួមមានៈ *កម្មវិធីទី ១* ការអប់រំទូទៅនិងការអប់រំក្រៅប្រព័ន្ធ *កម្មវិធីទី ២* ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ *កម្មវិធីទី ៣* យុវជននិងកីឡា *កម្មវិធីទី ៤* អភិបាលកិច្ច និងកំណែទម្រង់ស្ថាប័ន និង *កម្មវិធីទី ៥* ការគាំទ្រ និងការគ្រប់គ្រងសម្រាប់វិស័យអប់រំ។
- ថវិកាតាមកម្មវិធីភាគច្រើន គឺសំដៅលើកម្មវិធីទី ១ ដែលរាប់បញ្ចូលមត្តេយ្យសាលា សាលាបឋមសិក្សា និងសាលាមធ្យមសិក្សា ដែលមានលក្ខណៈផ្អែកលើរូបមន្តដោយប្រើសមាសភាគពីរគឺ (១) ប្រាក់ឧបត្ថម្ភទ្បេងទាត់សម្រាប់សាលារៀន និង (២) សមាសភាគផ្សេងៗអាស្រ័យលើចំនួនសិស្ស។ យោងតាមប្រកាសលេខ ១៩១ ថវិកា ២០០.០០០-៣០០.០០០ រៀលសម្រាប់មត្តេយ្យសាលាមួយ បូកនឹង ៦.០០០ រៀលសម្រាប់សិស្សម្នាក់ ហើយថវិកា ៥០០.០០០-៧០០.០០០ រៀលសម្រាប់សាលាបឋមសិក្សាមួយ បូកនឹង ៧.០០០-៨.០០០ រៀលសម្រាប់សិស្សម្នាក់ និងថវិកា ១.០-១.៥ លានរៀលសម្រាប់សាលាមធ្យមសិក្សាមួយ បូកនឹង ១៥.០០០-១៨.០០០ រៀលសម្រាប់សិស្សម្នាក់។
- ថវិកាតាមកម្មវិធីផ្សេងទៀត (កម្មវិធីទី ២-៥) គឺភាគច្រើនមិនមានផ្អែកលើរូបមន្តទេ។

ប្រភព: កិច្ចសម្ភាសន៍ជាមួយនាយកដ្ឋានថវិកា នៃក្រសួងអប់រំ យុវជន និងកីឡា *២៤ កុម្ភៈ ២០០៩*

ដូចបានលើកឡើងខាងលើ ជំនួយរបស់ម្ចាស់ជំនួយ (មិនរាប់បញ្ចូលការជួយគាំទ្រថវិកា) ត្រូវបានផ្ដល់ជូនភាគច្រើនតាមរយៈគម្រោង។ ហិរញ្ញប្បទានសម្រាប់គម្រោងទាំងនេះអាចរាប់បញ្ចូលចំណាយគ្រប់ប្រភេទទាំងអស់ (ឧទាហរណ៍ ចំណាយបុគ្គលិកលើការឧបត្ថម្ភបន្ថែមលើប្រាក់ខែ ការទិញរបស់ប្រើប្រាស់ ការវិនិយោគ)។ សម្រាប់គម្រោងអង្គការមិនមែនរដ្ឋាភិបាល ក៏មានលក្ខណៈដូចគ្នាអញ្ចឹងដែរ។ ផ្ទុយពីថវិកាជាតិដែលហូរតាមរយៈរចនាសម្ព័ន្ធផ្ដល់សេវាមិនសូវសាំញ៉ាំក្រោមក្រសួងអប់រំ យុវជន និងកីឡា ហិរញ្ញប្បទានរបស់ម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាល មានចំណាត់ការអនុវត្តផ្សេងៗគ្នា។

[៣] បទសម្ភាសន៍ជាមួយនាយកដ្ឋានថវិកា ក្រសួងអប់រំ យុវជន និង កីឡា ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០០៩។

## ៥.៣ រចនាសម្ព័ន្ធនៃការផ្តល់សេវា និងលំហូរមូលនិធិ

រចនាសម្ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡាត្រូវបានបែងចែកជាថ្នាក់កណ្តាល ខេត្ត ស្រុក សាលារៀន និងគណៈកម្មាធិការអប់រំក្នុងមូលដ្ឋាន។ គំនូសបង្ហាញទី២ ពន្យល់ពីរចនាសម្ព័ន្ធពាក់ព័ន្ធ និងលំហូរមូលនិធិ ខណៈដែលសេចក្តីអធិប្បាយនៅជាប់នោះ បង្ហាញថាតើថវិកាប្រភេទណាត្រូវបានបញ្ជូនទៅដល់ថ្នាក់ណា។

### គំនូសបង្ហាញទី ២: លំហូរថវិកា និងប្រភេទថវិកានៅកម្រិតនីមួយៗនៃការផ្តល់សេវា

**លំហូរហិរញ្ញវត្ថុក្នុងវិស័យអប់រំ**




**ប្រភេទថវិកានៅតាមកម្រិតនីមួយៗ**

- ក្រសួងអប់រំ យុវជន និងកីឡា: ប្រាក់បៀវត្សរ៍ O&M ការធ្វើថវិកាតាមកម្មវិធី ការជួយគាំទ្ររបស់ម្ចាស់ជំនួយ/អង្គការមិនមែនរដ្ឋាភិបាល
- មន្ទីរអប់រំ យុវជន និងកីឡា**ខេត្ត**: ប្រាក់បៀវត្សរ៍ O&M ការធ្វើថវិកាតាមកម្មវិធី ការជួយគាំទ្ររបស់ម្ចាស់ជំនួយ/អង្គការមិនមែនរដ្ឋាភិបាល
- ការិយាល័យអប់រំ យុវជន និងកីឡា**ស្រុក**: ប្រាក់បៀវត្សរ៍ ការផ្ទេរពីមន្ទីរអប់រំ យុវជន និងកីឡា**ខេត្ត** ការធ្វើថវិកាតាមកម្មវិធី ការជួយគាំទ្ររបស់ម្ចាស់ជំនួយ/អង្គការមិនមែនរដ្ឋាភិបាល
- សាលារៀន: ប្រាក់បៀវត្សរ៍ ការផ្ទេរពីមន្ទីរអប់រំ យុវជន និងកីឡា**ខេត្ត** ការធ្វើថវិកាតាមកម្មវិធី ការជួយគាំទ្ររបស់ម្ចាស់ជំនួយ/អង្គការមិនមែនរដ្ឋាភិបាល។

ប្រភព: អ្នកស្រាវជ្រាវ (២០០៩) យោងតាមកិច្ចសម្ភាសន៍ និងឯកសារពិគ្រោះ

ដូចមានក្នុងគំនូសបង្ហាញទី២ ការផ្តល់មូលនិធិពីថវិកាជាតិត្រូវបានវិភាជន៍ទៅឱ្យថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត គឺជាច្រកដែលថវិកាត្រូវបានផ្ទេរចុះទៅដល់ស្រុក និងសាលារៀន។ ផ្ទុយទៅវិញ ការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលភាគច្រើនត្រូវបានផ្តល់ដោយផ្ទាល់ ទៅឱ្យស្រុក និងសាលារៀនតាមរយៈគម្រោងផ្សេងៗ។ គួរកត់សម្គាល់ផងដែរថា ថវិកាជាតិភាគច្រើន គឺសម្រាប់ចាយលើចំណាយចរន្ត រីឯថវិកាពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល គឺសម្រាប់ថវិកាមូលធន ឬថវិកាអភិវឌ្ឍន៍ (សូមមើលផ្នែក ៥.២ ខាងលើអំពីនិយមន័យនៃចំណាយចរន្ត និងចំណាយមូលធន)។

## ៥.៤ យន្តការសម្របសម្រួល និងសុខុដុមនីយកម្មរាជរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល

ការពិភាក្សាជាមួយមន្ត្រីនៃនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា[៤] បានបង្ហាញថា ការបញ្ចេញប្រាក់ពីថវិកាជាតិ គឺមិនមានការពិបាកទេក្នុងការតាមដានមើលក្នុងគោលបំណងរដ្ឋបាល (ដូចដែលនឹងត្រូវបានពិភាក្សាខាងក្រោម ការបញ្ចេញប្រាក់ទាំងនេះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ ពោលគឺដើម្បីតែគោលបំណងគ្រប់គ្រងប៉ុណ្ណោះ) និងមិនសូវមានលក្ខណៈប្រមូលផ្តុំទេប្រៀបធៀបទៅនឹងហិរញ្ញប្បទាន ពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ ជាការពិតណាស់ អភិក្រមទូទាំងវិស័យសំដៅកាត់បន្ថយនូវបំណែក និងបង្កើនការតម្រង់ជំនួយទៅតាមអាទិភាពជាតិ។ ប៉ុន្តែដើម្បីឱ្យអភិក្រមទូទាំងវិស័យសម្រេចបាននូវគោលបំណងរបស់ខ្លួន ចាំបាច់ត្រូវមានការសម្របសម្រួលកាន់តែប្រសើរឡើងរវាង និងក្នុងចំណោមរាជរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ។ ក្នុងន័យនេះ យន្តការសម្របសម្រួលមួយចំនួនត្រូវបានបង្កើតឡើង។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីអប់រំ ត្រូវបានបង្កើតឡើង និងត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍នៃកម្ពុជាថាជា មធ្យោបាយគន្លឹះសម្រាប់ការសម្របសម្រួលរវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងដៃគូអភិវឌ្ឍន៍។ គេដឹងថាអង្គការUNICEF គឺជាម្ចាស់ជំនួយដ៏សកម្មបំផុតនៅក្នុងក្រុមការងារបច្ចេកទេសចម្រុះ។[៥]

អង្គការភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ(NEP) ត្រូវបានទទួលស្គាល់ជាតំណាងឱ្យអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងក្រុមការងារបច្ចេកទេសចម្រុះស្តីពីអប់រំ។ ភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ មានកៅអីចំនួនប្រាំកន្លែងនៅក្នុងក្រុមការងារបច្ចេកទេសចម្រុះស្តីពីអប់រំ និងក្រុមការងារវិស័យអប់រំ ហើយតាមរយៈក្រុមការងារទាំងនោះ ភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំអាចជួបដោយផ្ទាល់ជាមួយដៃគូអភិវឌ្ឍន៍។ ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ សមាជិកនៃភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ និងភាគីពាក់ព័ន្ធផ្សេងទៀត ចូលរួមក្នុងសន្និបាតអប់រំដែលឧបត្ថម្ភដោយរាជរដ្ឋាភិបាល ដើម្បីពិនិត្យមើលវឌ្ឍនភាពដែលសម្រេចបាននៅក្នុងវិស័យអប់រំ ក៏ដូចជាបញ្ហាមិនទាន់ដោះស្រាយនានា និងឱកាសសម្រាប់ធ្វើសកម្មភាព។

យន្តការសម្របសម្រួលមួយទៀតដែលមាន គឺកិច្ចប្រជុំជាន់ខ្ពស់ទៀងទាត់នៃរាជរដ្ឋាភិបាល និងក្រុមម្ចាស់ជំនួយ ជាមួយនឹងក្រុមការងារបច្ចេកទេសវិស័យសង្គមកិច្ច និងក្រុមប្រឹក្សាជាតិសម្រាប់អភិវឌ្ឍន៍សង្គមដែលជាផ្នែកមួយនៃការត្រៀមលក្ខណៈសម្រាប់កិច្ចប្រជុំក្រុមពិគ្រោះយោបល់ ដែលពេលនេះហៅថា វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា(CDCF)។ របាយការណ៍វឌ្ឍនភាព ត្រូវបានរៀបចំសម្រាប់គោលបំណងនៃកិច្ចប្រជុំ

[៤] បានធ្វើនៅថ្ងៃទី២៥ ខែតុលា និង ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅក្រសួងអប់រំ យុវជន និងកីឡា។

[៥] ដកស្រង់ពីការពិភាក្សាដែលបានធ្វើនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨។

ទាំងនេះ។ ដើម្បីបំពេញបន្ថែមយន្តការសម្របសម្រួលដែលមានរួចហើយ គេឃើញមានផែនការពង្រឹងសមត្ថភាពរបស់នាយកដ្ឋានផែនការនៃ ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាព និងហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ ម្យ៉ាងទៀត គោលនយោបាយវិស័យអប់រំឆ្នាំ២០០៦-២០១០ អំពាវនាវឱ្យមានការពង្រឹង និងសកម្មភាពសហការគ្នាបន្ថែមទៀត ឱ្យបានលើសពីការតាមដាន និងការរាយការណ៍រួមអំពីការបំពេញការងារក្នុងវិស័យ។

ប៉ុន្តែទោះបីជាមានកិច្ចប្រឹងប្រែងទាំងអស់ដែលបានលើកឡើងខាងលើក្តី គេនៅតែមិនអាចយល់ដឹងឱ្យបានពេញលេញ ថាតើមានហិរញ្ញប្បទានចំនួនប៉ុន្មានដែលត្រូវបានផ្តល់ជូនវិស័យអប់រំ និងថាតើប្រាក់ទាំងនេះបានរួមចំណែកយ៉ាងដូចម្តេចដល់ការសម្រេចបានគោលដៅទាំងឡាយនៃគោលនយោបាយវិស័យអប់រំ។ ជាក់ស្តែងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលលើហិរញ្ញប្បទានសម្រាប់វិស័យអប់រំនៅតែមានលក្ខណៈជាបំណែក។ វិភាជន៍ថវិកាជាតិត្រូវបានត្រួតពិនិត្យដោយនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា ខណៈដែលការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានត្រួតពិនិត្យដោយនាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការិយាល័យសម្របសម្រួលជំនួយរបស់នាយកដ្ឋាន។ ដូចដែលការពិភាក្សាបន្ទាប់នឹងបង្ហាញជូន ព័ត៌មានស្តីពីថវិកាជាតិគឺមានលក្ខណៈមជ្ឈការ ខណៈដែលព័ត៌មានស្តីពីហិរញ្ញប្បទានផ្តល់ដោយម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាល មានលក្ខណៈជាបំណែក។ ការដាក់បញ្ចូលគ្នានូវហិរញ្ញប្បទានទាំងពីរគឺជាបញ្ហាប្រឈមមួយសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ម្ចាស់ជំនួយ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល។ កិច្ចពិភាក្សាជាបន្តនឹងធ្វើឡើង ដោយហេតុថាក្រសួងកំពុងធ្វើផែនការដើម្បីដាក់ឱ្យអនុវត្តនូវការប្រើផែនការប្រតិបត្តិការប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីដាក់បញ្ចូលគ្នានូវប្រភពផ្តល់មូលនិធិផ្សេងៗគ្នាទាំងនេះ។

## ៦. ព័ត៌មានថវិកា និងការចេញផ្សាយព័ត៌មាននេះនៅកម្រិតផ្សេងៗគ្នា

ការពិភាក្សានៅក្នុងផ្នែកនេះ ផ្តោតលើឯកសារ និងព័ត៌មានស្តីពីថវិកា។ ផ្នែកនេះនឹងកំណត់ថាតើឯកសារនិងព័ត៌មានស្តីពីថវិកាអ្វីខ្លះដែលអាចរកបានពីថ្នាក់កណ្តាលរហូតដល់កម្រិតសាលារៀន/សហគមន៍។ សម្រាប់ឯកសារស្តីពីថវិកានីមួយៗ នឹងមានការកំណត់ថាតើឯកសារនេះត្រូវបានរៀបចំ:

- យ៉ាងទៀងទាត់ឬទេ? បើទៀងទាត់មែន តើញឹកញាប់ប៉ុណ្ណា?
- សម្រាប់តែគោលបំណងប្រើប្រាស់ផ្ទៃក្នុងប៉ុណ្ណោះ ពោលគឺមិនមែនផ្សព្វផ្សាយជាសាធារណៈទេ?
- ផ្សព្វផ្សាយជាសាធារណៈតែក្នុងករណីមានសំណើផ្លូវការប៉ុណ្ណោះ?

នៅគ្រប់កន្លែងដែលអាចពាក់ព័ន្ធនានា ការពិភាក្សានឹងបង្ហាញច្បាស់ថាតើប្រភេទព័ត៌មានអ្វីខ្លះដែលអាចផ្សព្វផ្សាយបាន:

- ជូនសាធារណជនទូទៅ
- យ៉ាងទៀងទាត់ជូនសមាជិកនៃក្រុមការងារបច្ចេកទេសនៅថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាបញ្ជាក់ថាព័ត៌មាននេះអាចផ្សព្វផ្សាយជាសាធារណៈ និង
- យ៉ាងទៀងទាត់ជូនសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបរិក្ខាររូបវ័ន្ត និងក្រុមប្រឹក្សាក្នុងមូលដ្ឋានផ្សេងទៀត ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាបញ្ជាក់ថាព័ត៌មាននេះអាចផ្សព្វផ្សាយជាសាធារណៈ ។

## ៦.១ ថ្នាក់ជាតិ

### ស្ដីពីថវិកាជាតិ

គេឃើញមានស្ថាប័នផ្សេងៗដែលរៀបចំ និងបោះផ្សាយឯកសារស្ដីពីថវិកាជាតិជារួម និងដោយឡែកសម្រាប់វិស័យអប់រំ ។ រដ្ឋសភាអនុម័តនិងចេញ***ច្បាប់ថវិកាជាតិ***។ ចាប់តាំងពីឆ្នាំ២០០៧មក ច្បាប់នេះបានដាក់បញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធនដែលត្រូវបានឧបត្ថម្ភមូលនិធិដោយម្ចាស់ជំនួយដែលត្រូវបានបែងចែកតាមវិស័យ/ក្រសួង ។ ថវិកាចរន្ត បង្ហាញបរិមាណវិភាជន៍តាមស្ថាប័នរាជរដ្ឋាភិបាលនីមួយៗ (និងការវិភាជន៍រវាងថ្នាក់កណ្ដាល និងថ្នាក់ខេត្ត) ហើយថវិកាមូលធនបង្ហាញបញ្ជីគម្រោងនានាតាមស្ថាប័នរាជរដ្ឋាភិបាលនីមួយៗ។ ជារៀងរាល់ឆ្នាំ ប្រហែលជានៅក្នុងខែមីនា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បោះផ្សាយ ផងដែរនូវ***ឯកសារថវិកាជាតិមួយដែលមានបួនភាគ*** ដែលផ្ដល់ព័ត៌មានលម្អិតអំពីរបៀបដែលថវិកាត្រូវបានវិភាជន៍គិតតាមវិស័យ និងតាមខេត្ត[៦] ។ ចំពោះវិស័យអប់រំ គេអាចរកបានព័ត៌មានដូចខាងក្រោម:

- *សៀវភៅភាគទី ១:* ថវិកាជាតិដែលដាក់បញ្ចូលទាំងការគ្រប់គ្រងសេចក្ដីនៃថវិកាជាតិដូចដែលត្រូវបានអនុម័តដោយរដ្ឋសភា រួមជាមួយការវិភាគសារពើពន្ធលើលទ្ធផលសេដ្ឋកិច្ច ព្យាករណ៍ របៀបវារៈកំណែទម្រង់ផ្សេងៗប្រចាំឆ្នាំ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលត្រូវបានចេញផ្សាយនៅក្នុងឆ្នាំ ទាក់ទិននឹងបញ្ហាគ្រប់គ្រងថវិកា ។
- *សៀវភៅភាគទី ២:* ការវិភាជន៍ថវិកាសម្រាប់ក្រសួងកណ្ដាល ដែលបង្ហាញព័ត៌មានលម្អិតនៃការវិភាជន៍ថវិកាក្រសួង តាមថ្នាក់កណ្ដាល និងខេត្ត និងសម្រាប់ខេត្តនីមួយៗ ។ ឯកសារនេះរាប់បញ្ចូលតែចំណាយចរន្តប្រចាំឆ្នាំប៉ុណ្ណោះ ។
- *សៀវភៅភាគទី ៣:* ការវិភាជន៍ថវិកាតាមខេត្ត ដែលផ្ដល់ព័ត៌មានលម្អិតអំពីការវិភាជន៍តាមមន្ទីរពាក់ព័ន្ធ ។ ឯកសារនេះដាក់បញ្ចូលតែចំណាយចរន្តប៉ុណ្ណោះ ។

[៦] ការជួបប្រជុំជាមួយមន្ត្រីនៃនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ ២០០៩ ។

- *សៀវភៅភាគទី ៤:* ការបែងចែកថវិកាទៅឱ្យអាជ្ញាធរខេត្ត ដែលជាធម្មតាគេហៅថា*សាលាខេត្ត* ដែលផ្តល់ព័ត៌មានលម្អិតតាមខេត្ត។ គេគប្បីកត់សម្គាល់ថាមូលនិធិនេះ (ពោលគឺសម្រាប់សាលាខេត្ត) រាប់បញ្ចូលទាំងចំណាយចរន្ត និងមួយចំណែកតូចនៃចំណាយមូលធន។

ឯកសារដែលបានលើកឡើងខាងលើនេះ អាចត្រូវបានប្រើរួមជាមួយ ***កម្មវិធីវិនិយោគសាធារណៈ (PIP)*** ដែលគឺជាផែនការវិនិយោគរំកិលរយៈពេលបីឆ្នាំសម្រាប់គ្រប់វិស័យទាំងអស់ ដើម្បីមានការយល់ដឹងទាំងស្រុងអំពីថវិកាចរន្ត និងថវិកាមូលធនសម្រាប់វិស័យទាំងមូល។ កម្មវិធីវិនិយោគសាធារណៈត្រូវបានបោះផ្សាយដោយ (និងអាចរកបានពី) ក្រសួងផែនការ និងត្រូវបានធ្វើបច្ចុប្បន្នកម្មរៀងរាល់ឆ្នាំ និងបោះផ្សាយនៅដើមឆ្នាំ។ នៅក្នុងកម្មវិធីវិនិយោគសាធារណៈ វិស័យអប់រំត្រូវបានចាត់ថ្នាក់នៅក្នុងវិស័យសង្គមកិច្ចរួមជាមួយវិស័យសុខាភិបាល។ ឯកសារនេះក៏បង្ហាញផងដែរនូវបញ្ជីនៃគម្រោងនានាសម្រាប់ការអប់រំកម្រិតមូលដ្ឋាន ឧត្តមសិក្សា ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មធ្យមសិក្សា យុវជន និងកីឡា។ ក្រោមប្រភេទនីមួយៗ ឯកសារនេះបង្ហាញគម្រោងអាទិភាពកំពុងដំណើរការ និងគម្រោងបម្រុងដែលត្រូវបែកចេញថែមទៀតទៅជាការវិនិយោគមូលធន និងគម្រោងជំនួយបច្ចេកទេស។ គេក៏គប្បីកត់សម្គាល់ផងដែរថា គម្រោងកម្មវិធីវិនិយោគសាធារណៈក៏ត្រូវបានដាក់បញ្ចូលផងដែរនៅក្នុងផ្នែកមូលធន (តារាង គ និង ឃ) នៃថវិកាជាតិ។

ចំពោះការអនុវត្តថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយទទួលបានព័ត៌មានពីរតនាគារជាតិ ចេញរបាយការណ៍ប្រចាំខែមួយស្តីពីការអនុវត្តថវិការដ្ឋ ដែលគេស្គាល់ថាជា ***តារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ (TOFE)***[៧]។ តារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋត្រូវបានរៀបចំប្រចាំខែ ហើយអាចទិញបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ឯកសារនេះគឺជាឯកសារយោងដ៏ល្អមួយអំពីការអនុវត្តប្រចាំខែនូវថវិកាជាតិ និងការជួយគាំទ្ររបស់ម្ចាស់ជំនួយ។

ប្រភពព័ត៌មានពីរផ្សេងទៀតស្តីពីហិរញ្ញប្បទានវិស័យអប់រំ គប្បីត្រូវបានលើកឡើងនៅទីនេះ។ ចំពោះការជួយគាំទ្ររបស់ម្ចាស់ជំនួយ ***មូលដ្ឋានទិន្នន័យស្តីពីហិរញ្ញប្បទានអភិវឌ្ឍន៍អន្តរជាតិរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*** គឺជាប្រភពទិន្នន័យដ៏ល្អមួយ ថ្វីបើមិនល្អឥតខ្ចោះក្តី។ ដោយត្រូវបានធ្វើបច្ចុប្បន្នកម្មយ៉ាងទៀងទាត់ និងផ្សព្វផ្សាយជាសាធារណៈ មូលដ្ឋានទិន្នន័យនេះផ្តល់ព័ត៌មានអំពីការបញ្ចេញមូលនិធិប្រចាំឆ្នាំពីម្ចាស់ជំនួយផ្សេងៗ។ ប៉ុន្តែមូលដ្ឋានទិន្នន័យនេះមានលក្ខណៈពិបាកប្រើ។ លើសពីនេះទៀត ព័ត៌មានស្តីពីការបញ្ចេញប្រាក់ដោយម្ចាស់ជំនួយទៅក្នុងគម្រោង/កម្មវិធី គឺអាចរកបាន ប៉ុន្តែមិនមានព័ត៌មានអំពីមូលនិធិដែលត្រូវបានបញ្ចេញពីគម្រោង ឬកម្មវិធីនីមួយៗ[៨]។ ប្រព័ន្ធទិន្នន័យស្តីពីជំនួយអភិវឌ្ឍន៍អន្តរជាតិរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចចូលមើលបាននៅលើគេហទំព័រ: http://cdc.khmer.biz/ ។

[៧] Tableau des Opérations Financières de l'Etat

[៨] លីណើត (Lienert, I.) ហេលីស (J. Helis) និង អ្នកដទៃ (២០០៨)។ កម្ពុជា: កែលម្អគណនេយ្យរបស់រាជរដ្ឋាភិបាល។ ភ្នំពេញ, មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។

ខណៈដែលព័ត៌មានអាចរកបានជាសាធារណៈក្នុងកម្រិតច្រើនបង្គួរ ឯកសារថវិកាដែលបានលើកឡើងខាងលើ ភាគច្រើនផ្តល់តែទិន្នន័យសរុប។ សម្រាប់គោលបំណងតាមដាន និងវិភាគការវិភាជន៍ ព្រមទាំងការអនុវត្តថវិកានៅក្នុងវិស័យជាក់លាក់មួយ ដូចជាវិស័យអប់រំជាដើម ទិន្នន័យលម្អិតគឺចាំបាច់។ ព័ត៌មានសរុបមិនអនុញ្ញាតឱ្យអ្នកវិភាគ ផ្សារភ្ជាប់ទៅនឹងអ្វីដែលត្រូវបានចំណាយ និងអ្វីដែលសម្រេចបានជាមួយចំណាយទាំងនេះ ហើយវាក៏មិនអនុញ្ញាតឱ្យមានការវិភាគលម្អិតបន្ថែមទៀតទេ ឧទាហរណ៍ អតុល្យភាពភូមិសាស្ត្រនៅក្នុងរបៀបដែលថវិកាត្រូវបានវិភាជន៍។

ព័ត៌មានកាន់តែលម្អិតគឺរកបានពីក្រសួងអប់រំ យុវជន និងកីឡាតែម្តង។ នាយកដ្ឋានគាំទ្រមួយចំនួនរបស់ក្រសួង ផលិតទិន្នន័យនិងថែរក្សាមូលដ្ឋានទិន្នន័យ ដែលមានប្រយោជន៍ខ្លាំងសម្រាប់ការវិភាគថវិកា។ ទីមួយគឺនាយកដ្ឋានផែនការ។ បទសម្ភាសន៍ជាមួយមន្ត្រីនាយកដ្ឋានផែនការបង្ហាញថា នាយកដ្ឋាននេះផលិត និងរក្សាទុកមូលដ្ឋានទិន្នន័យ និងរបាយការណ៍មួយចំនួន។ នាយកដ្ឋានផែនការ រៀបចំជារៀងរាល់ឆ្នាំនូវ ***ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងវិស័យអប់រំ (EMIS)*** ដែលផ្អែកលើនោះ **ស្ថិតិ និងអាំងឌីកាទ័រអប់រំជាតិ**ត្រូវបានបង្កើត និងផ្សព្វផ្សាយជាសាធារណៈនៅក្នុងអំឡុងខែកុម្ភៈ ដល់ ខែឧសភា ជារៀងរាល់ឆ្នាំ។ ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងវិស័យអប់រំដាក់បញ្ចូលព័ត៌មានសំខាន់ៗទាំងអស់ រួមមាន ការចុះឈ្មោះចូលរៀនរបស់សិស្ស អត្រាបោះបង់ការសិក្សា និងចំនួនសាលារៀន និងថ្នាក់រៀន។ ស្ថិតិ និងអាំងឌីកាទ័រអប់រំដែលចេញពីប្រព័ន្ធព័ត៌មាននេះ គឺគ្រប់គ្រាន់សម្រាប់អ្នក ដែលចាប់អារម្មណ៍លើការបំពេញការងារក្នុងវិស័យអប់រំ។ បន្ថែមលើនេះ នាយកដ្ឋានផែនការក៏ផលិតជារៀងរាល់ឆ្នាំផងដែរនូវរបាយការណ៍សំខាន់ៗ ដូចជា ***របាយការណ៍រួមស្តីពីការងារ ប្រចាំឆ្នាំ និងរបាយការណ៍បូកសរុបការងារក្នុងវិស័យអប់រំ***។ របាយការណ៍ទាំងនេះ ជាធម្មតាត្រូវបានបញ្ចប់និងផ្សព្វផ្សាយជាសាធារណៈមុនដំណាច់ខែមីនា រៀងរាល់ឆ្នាំ។

នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា ដែលទទួលបន្ទុកលើការវិភាជន៍ថវិកាជាតិ ក៏ផលិតឯកសារថវិកាមួយចំនួនក្នុងគោលបំណងនៃការរៀបចំ ការប្រតិបត្តិ និងការត្រួតពិនិត្យថវិកា។ ឯកសារមួយក្នុងចំណោមឯកសារថវិកាទាំងនេះ គឺ ***ផែនការថវិកាប្រចាំឆ្នាំ*** ដែលនាយកដ្ឋានហិរញ្ញវត្ថុរៀបចំ ហើយបន្ទាប់មកដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបន្ទាប់មកដាក់ជូនរដ្ឋសភា។ ផែនការថវិកាប្រចាំឆ្នាំនេះមានទម្រង់ដូចគ្នានឹងឯកសារស្តីពីការគ្រប់គ្រងថវិការបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (សៀវភៅទី ២)។ គេគួរកត់សម្គាល់ថា តួលេខនៅក្នុងឯកសារគ្រប់គ្រងថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាការវិភាជន៍ជាក់ស្តែង ហើយតួលេខនៅក្នុងផែនការថវិកាប្រចាំឆ្នាំ គឺគ្រាន់តែជាសំណើ ដែលដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប៉ុណ្ណោះ។ យោងតាមច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៨ ផែនការថវិកាបែបនេះចាំបាច់ត្រូវដាក់ឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនខែសីហា។ ជាធម្មតា ផែនការនេះមិនអាចផ្សព្វផ្សាយជាសាធារណៈបានទេ លុះត្រាណាតែមានការអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា។ ឯកសារមួយទៀត គឺ ***របាយការណ៍ប្រចាំខែស្តីពីការអនុវត្តថវិកា*** ដែលរាប់បញ្ចូលគ្រប់ជំពូកថវិកាទាំងអស់ដែលធ្វើហិរញ្ញប្បទានដោយថវិកាជាតិ ទាំងនៅថ្នាក់

កណ្តាល និងនៅថ្នាក់ខេត្ត។ របាយការណ៍នេះ ដាក់បញ្ចូលប្រាក់បៀវត្សរ៍ ប្រតិបត្តិការ និងការរក្សាថវិកាតាមកម្មវិធី និងចំណាយចរន្តតូចតាចផ្សេងទៀត[៩]។ របាយការណ៍នេះ គឺមានទម្រង់ដូចគ្នានឹងផែនការថវិកាប្រចាំឆ្នាំនៃឯកសារគ្រប់គ្រងថវិកា។ នាយកដ្ឋានហិរញ្ញវត្ថុក៏រក្សាទុកផងដែរនូវប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS)។ ប៉ុន្តែយោងតាមបទសម្ភាសន៍ជាមួយមន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុនៅមិនទាន់បានដំណើរការសមស្របនៅឡើយ។

ដូចចំណាយមូលធនដែរ នៅក្នុងវិស័យអប់រំ ហិញ្ញប្បទានមានពីរផ្នែក: មួយផ្នែកគឺហិញ្ញប្បទានក្នុងប្រទេស ហើយមួយផ្នែកទៀតគឺហិរញ្ញប្បទានបរទេស។ នៅក្នុងប្រព័ន្ធបច្ចុប្បន្ន ចំណាយមូលធនទាំងមូលដែលត្រូវបានចែកចេញជាគម្រោងឬកម្មវិធីអភិវឌ្ឍន៍រាប់រយ ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ថ្វីបើនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ មិនមានផលិតឯកសារសាធារណៈស្តីពីគម្រោងថវិកាឬការអនុវត្តថវិកាក្តី ក៏នាយកដ្ឋាននេះផ្តល់ព័ត៌មានដែលត្រូវបានដាក់បញ្ចូលក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដែរ[១០]។ ហិរញ្ញប្បទានក្នុងប្រទេសទាំងអស់ និងមួយផ្នែកនៃចំណាយមូលធនដែលត្រូវបានផ្តល់មូលនិធិពីបរទេស ត្រូវបានចាយ(បញ្ចេញ)តាមរយៈប្រព័ន្ធរតនាគារជាតិ ដូច្នេះការប្រតិបត្តិចំណាយទាំងនេះត្រូវបានកត់ត្រាដោយរតនាគារជាតិ និងបញ្ជូនទៅឱ្យនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ការរៀបចំតារាងប្រតិបត្តិការហិរញ្ញវត្ថុប្រចាំខែរបស់រដ្ឋ។ សម្រាប់ការផ្តល់មូលនិធិបរទេសទាំងឡាយដែលមិនត្រូវបានធ្វើតាមរយៈប្រព័ន្ធរតនាគារ ព័ត៌មានស្តីពីការប្រតិបត្តិមូលនិធិទាំងនេះអាចទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ប៉ុន្តែ ដូចដែលបានពិភាក្សាខាងលើ កំណត់ត្រាអំពីការជួយគាំទ្ររបស់ម្ចាស់ជំនួយ (ដែលការជួយគាំទ្រមួយចំនួនត្រូវបានផ្តល់តាមរយៈអង្គការមិនមែនរដ្ឋាភិបាល) នៅតែមិនទាន់មានលក្ខណៈពេញលេញនៅឡើយ ទាំងនៅក្នុងករណីនៃមូលដ្ឋានទិន្នន័យស្តីពីហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមូលដ្ឋានទិន្នន័យដែលទើបបង្កើតនាពេលថ្មីៗរបស់នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ[១១]។

ព័ត៌មានដែលមាននៅក្នុងឯកសារ មូលដ្ឋានទិន្នន័យ និងរបាយការណ៍ថវិកាដែលបានលើកឡើងខាងលើ គឺមានប្រយោជន៍ខ្លាំង។ ព័ត៌មានទាំងនេះ គឺចាំបាច់នៅក្នុងការវាយតម្លៃ និងការតាមដានក្នុងវិស័យ ដោយយោងលើល័ក្ខខ័ណ្ឌគ្រប់គ្រងថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នសវនកម្មពាក់ព័ន្ធ។ គួរឱ្យសោកស្តាយ យោងតាមមន្ត្រីថ្នាក់កណ្តាលដែលបានសម្ភាសន៍ ព័ត៌មានទាំងនេះអាចរកបានតែនៅពេលណា ដែលមាន

---

[៩] ព័ត៌មានលម្អិតបន្ថែមស្តីពីប្រាក់បៀវត្សរ៍ និងបុគ្គលិកទាក់ទិននឹងចំណាយ ត្រូវបានរក្សាទុកនៅនាយកដ្ឋានបុគ្គលិកនៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS)។ ផ្ទុយទៅវិញ ព័ត៌មានបន្ថែមទៀតស្តីពីសារពើភ័ណ្ឌ/ទ្រព្យសម្បត្តិ គឺមាននៅ នាយកដ្ឋានទ្រព្យសម្បត្តិនៃក្រសួងអប់រំ យុវជន និងកីឡា។

[១០] ការជួបប្រជុំជាមួយមន្ត្រីនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៩។

[១១] ផ្អែកលើបទសម្ភាសន៍ជាមួយមន្ត្រីរតនាគារជាតិ (ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៨)។

ការយល់ព្រមជាផ្លូវការពីថ្នាក់លើ ពោលគឺថ្នាក់រដ្ឋមន្ត្រី។ លិខិតស្នើសុំមួយចាំបាច់ត្រូវដាក់ជូន ហើយលិខិតនេះនឹងត្រូវឆ្លងកាត់នីតិវិធីរដ្ឋបាលដែលពាក់ព័ន្ធ។ ហេតុដូច្នេះ គេអាចចំណាយពេលរាប់សប្តាហ៍មុនពេលគេដឹងថាតើសំណើនោះត្រូវបានយល់ព្រម ឬទេ។ ដោយមានការយល់ព្រម គេអាចទទួលបានទិន្នន័យយ៉ាងច្រើនតាមដែលគេអាច។ ហេតុដូច្នេះ វាគឺជាស្ថានភាពមួយដែលមានលក្ខណៈ "បានទាំងអស់ ឬមិនបានសោះ" ក្នុងការស្នើសុំព័ត៌មានបែបនេះ។

ជាមួយសំណើផ្លូវការដែលត្រូវបានឯកភាពដោយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ក្រុមការងារបច្ចេកទេសចម្រុះស្តីពីការអប់រំត្រូវបានគេផ្តល់ព័ត៌មានខាងលើនេះ ពោលគឺព័ត៌មានស្តីពីការវិភាជន៍ និងការអនុវត្តថវិកា។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីការអប់រំ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងៗបានបង្ហាញថាមានប្រយោជន៍ខ្លាំង។ សំណើរបស់ក្រុមការងារ គឺមានទម្ងន់ច្រើន។ មានការអះអាងថាព័ត៌មានភាគច្រើនដែលត្រូវបានផ្តល់ជូនក្រុមការងារបច្ចេកទេសចម្រុះ អាចចែករំលែកជាមួយភាគីពាក់ព័ន្ធផ្សេងទៀតបាន។ ប៉ុន្តែ នៅពេលដែលត្រូវបានសួរថាតើព័ត៌មាននេះអាចផ្សព្វផ្សាយជូនសាធារណជនទូទៅឬទេ មន្ត្រីដែលផ្តល់បទសម្ភាសន៍បានសួរថា តើចង់និយាយអំពីសាធារណជនទូទៅបែបណា។ ប្រការនេះគឺចង់និយាយថាតម្លាភាពទាំងស្រុងប្រហែលជាមិនទាន់អាចរំពឹងបានទេនៅពេលនេះ។

### ការគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល

ផ្អែកលើការពិភាក្សាខាងលើ គេមើលឃើញថាមានព័ត៌មានច្រើនគួរសមដែលត្រូវបានផលិតស្តីពីការវិភាជន៍ថវិកាជាតិសម្រាប់វិស័យអប់រំ។ ប៉ុន្តែ ការចេញផ្សាយព័ត៌មាន និងលទ្ធភាពរកបានព័ត៌មាននេះ មានលក្ខណៈមជ្ឈការ និងត្រួតពិនិត្យច្រើន ដែលជាញឹកញាប់តម្រូវឱ្យមានសំណើផ្លូវការ និងការយល់ព្រមលើសំណើបែបនេះពីថ្នាក់លើ។ ចំពោះព័ត៌មានស្តីពីការគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល គេបានរកឃើញរូបភាពខុសគ្នាមួយ ដោយព័ត៌មាននោះមានលក្ខណៈបែកខ្ញែក។ ជាផ្លូវការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងផែនការ និងក្រសួងអប់រំ យុវជន និងកីឡា គឺជាស្ថាប័នរាជរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងការសម្របសម្រួលការជួយគាំទ្ររបស់ម្ចាស់ជំនួយ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានផលិត និងធ្វើបច្ចុប្បន្នកម្មយ៉ាងទៀងទាត់នូវ ***មូលដ្ឋានទិន្នន័យស្តីពីហិរញ្ញប្បទានអភិវឌ្ឍន៍អន្តរជាតិ*** ដើម្បីតាមដានការជួយគាំទ្ររបស់ម្ចាស់ជំនួយ ជារួមនិងតាមវិស័យ។ នៅក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានផែនការក៏បានព្យាយាមបង្កើតមូលដ្ឋានទិន្នន័យមួយ ដើម្បីតាមដានការគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ ប៉ុន្តែ យោងតាមបទសម្ភាសន៍ជាមួយមន្ត្រីនាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡា ព័ត៌មានដែលបានផ្តល់ពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីធ្វើបច្ចុប្បន្នកម្មមូលដ្ឋានទិន្នន័យ មានលក្ខណៈមិនច្បាស់លាស់ ហើយនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ។

ប៉ុន្តែ ផ្នែកមួយចំនួននៅត្រូវការកែលម្អបន្ថែមទៀត ។ ទីមួយ មូលដ្ឋានទិន្នន័យស្តីពីហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ នៅមិនទាន់មានលក្ខណៈងាយប្រើនៅឡើយ ។ មានតែអ្នកដែលមានចំណេះដឹងខ្លះអំពីមូលដ្ឋានទិន្នន័យ និងការគ្រប់គ្រងព័ត៌មានវិទ្យាប៉ុណ្ណោះដែលអាចប្រើវាបានល្អ ។ ទីពីរ មូលដ្ឋានទិន្នន័យនេះពឹងផ្អែកលើព័ត៌មានដែលផ្ញើឱ្យដោយស្ម័គ្រចិត្តពីម្ចាស់ជំនួយ ។ ម្ចាស់ជំនួយទាំងអស់នៅមិនទាន់សហការពេញលេញនៅឡើយទេនៅក្នុងការងារនេះ ។ ទីបី មូលដ្ឋានទិន្នន័យនេះនៅមិនទាន់មានលក្ខណៈពេញលេញ និងត្រឹមត្រូវគ្រប់គ្រាន់នៅឡើយ ។ គេឃើញមានបញ្ហានៃការរាប់ត្រួតគ្នា និងការធ្វើចំណាត់ថ្នាក់មិនស្របគ្នា[១២] ។

ចំពោះការជួយគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលវិញ គេពុំឃើញមានមូលដ្ឋានទិន្នន័យ ឬប្រព័ន្ធសម្របសម្រួលណាមួយសម្រាប់តាមដានហិរញ្ញប្បទាននេះជារួម ឬតាមវិស័យឡើយ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានទិន្នន័យខ្លះស្តីពីការជួយគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាល ហើយជាក់ស្តែងទើបតែចេញរបាយការណ៍មួយនៅពេលថ្មីៗនេះស្តីពីអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលធ្វើការនៅកម្ពុជា និងសកម្មភាពរបស់អង្គការទាំងនេះ ។ ប៉ុន្តែ របាយការណ៍នេះហាក់បីដូចជាមិនត្រូវបានធ្វើបច្ចុប្បន្នកម្ម ឬចេញឱ្យបានទៀងទាត់ឡើយ (ឧទាហរណ៍ ប្រចាំឆ្នាំ) ។ នៅក្រសួងមហាផ្ទៃមាននាយកដ្ឋានមួយទទួលបន្ទុកលើការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែសូម្បីតែនៅកន្លែងនោះ ការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលគឺមានលក្ខណៈមិនទាន់រលូននៅឡើយ ។

នៅក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានផែនការ តាមរយៈការិយាល័យសម្របសម្រួលជំនួយរបស់ខ្លួន គឺជានាយកដ្ឋានដែលទទួលខុសត្រូវលើការតាមដានការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងសកម្មភាពអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងវិស័យអប់រំ ។ នីតិវិធីសមស្របគឺថាម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលចាំបាច់ត្រូវទាក់ទងនាយកដ្ឋានផែនការនៅពេលធ្វើផែនការដើម្បីផ្តល់ការជួយគាំទ្រខាងហិរញ្ញវត្ថុ ឬធ្វើសកម្មភាពអ្វីមួយ ។ ក្រោយពេលដែលគម្រោង ឬអង្គការមិនមែនរដ្ឋាភិបាលត្រូវបានបង្កើតឡើងនិងដំណើរការ ការធ្វើបច្ចុប្បន្នកម្មទៀងទាត់ស្តីពីស្ថានភាពហិរញ្ញប្បទាន/សកម្មភាពរបស់ខ្លួន ចាំបាច់ត្រូវផ្តល់ជូននាយកដ្ឋានផែនការ ។ ដើម្បីគ្រប់ គ្រងកិច្ចដំណើរការនេះ នាយកដ្ឋានផែនការបានបង្កើតប្រព័ន្ធទិន្នន័យមួយដែលមានឈ្មោះថា ***"ប្រព័ន្ធព័ត៌មាន គ្រប់គ្រងជំនួយ"*** ។ ប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយត្រូវបានគ្រោងធ្វើបច្ចុប្បន្នកម្មរៀងរាល់ឆ្នាំជាមួយព័ត៌មានដែល បានស្នើសុំពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ។ រៀងរាល់ឆ្នាំ នាយកដ្ឋានផែនការផ្ញើចេញនូវកម្រងសំណួរមួយជូនដល់គ្រប់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ។ ចំពោះផ្នែកអង្គការមិនមែនរដ្ឋាភិបាល នាយកដ្ឋានផែនការទាក់ទងច្រើនជាមួយភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំនៅក្នុងកិច្ចដំណើរការនេះ ។ ឆ្នាំនេះ របាយការណ៍ពីរដែលប្រើប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយត្រូវបាន

[១២] ឧទាហរណ៍ ដូចដែលបានបង្ហាញនៅក្នុងបទសម្ភាសន៍ ការកំណត់អង្គភាពគ្រប់គ្រងគម្រោង (PMU) នៅមិនទាន់ច្បាស់លាស់ នៅឡើយ ។ គេឃើញមានលទ្ធភាពខ្ពស់នៃការរាប់ត្រួតគ្នាផងដែរ ដោយសារស្ថាប័នលើសពីមួយអាចបានរាយការណ៍អំពីការមានអង្គភាពគ្រប់គ្រងគម្រោងដូច គ្នា ។ បញ្ហាទាំងនេះត្រូវបានទទួលស្គាល់ដោយក្រុមការងារនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលធ្វើការលើបញ្ហាសម្របសម្រួលជំនួយ ហើយពួកគេកំពុងចាត់វិធានការដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

ផលិត គឺមូលដ្ឋានទិន្នន័យស្តីពីគម្រោងជំនួយនៅក្នុងវិស័យអប់រំ និងរបាយការណ៍ស្តីពីការសាងសង់សាលារៀន។ របាយការណ៍ទាំងពីរនេះ គ្រោងចេញមុនពេលសន្និបាតអប់រំក្នុងខែមីនា ប៉ុន្តែដោយសារការងារច្រើន និងសមត្ថភាពមានកម្រិតរបស់បុគ្គលិក ការបញ្ចេញរបាយការណ៍ទាំងពីរនេះត្រូវបានពន្យាររហូតដល់ខែកក្កដា។ មន្ត្រីនាយកដ្ឋានផែនការកំពុងធ្វើការកែលម្អលើភាពពេញលេញ និងភាពទាន់ពេលវេលានៃការចេញរបាយការណ៍ និងព័ត៌មានពាក់ព័ន្ធ។

ផ្អែកលើការលើកឡើងខាងលើ គេអាចសន្និដ្ឋានបានថាព័ត៌មានស្តីពីហិរញ្ញប្បទានទាំងអស់ចំពោះវិស័យអប់រំមិនទាន់ពេញលេញទេ។ ដំណោះស្រាយចំពោះបញ្ហានេះស្ថិតនៅលើប្រការដែលថា តើម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធសុខចិត្តចែករំលែកព័ត៌មានឱ្យបានទៀងទាត់ និងជាប្រព័ន្ធឬទេជាមួយនាយកដ្ឋានផែនការ និងថាតើសមត្ថភាពរបស់នាយកដ្ឋានផែនការបានកែលម្អដល់កម្រិតមួយ ដែលគ្រប់គ្រាន់ដើម្បីធ្វើការងារសម្របសម្រួលនេះ។

## ៦.២ ថ្នាក់ខេត្ត និងស្រុក: ថវិកាជាតិ និងការជួយគាំទ្ររបស់ម្ចាស់ជំនួយ/អង្គការមិនមែនរដ្ឋាភិបាល

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត គឺជាស្ថាប័នថ្នាក់ក្រោមជាតិខ្ពស់បំផុតនៃវិស័យអប់រំ។ រៀងរាល់ឆ្នាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តរៀបចំ ***ថវិកាប្រចាំឆ្នាំ*** ជូនការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងសាលារៀន។ ក្រោមចំណាត់ការបែបនេះ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត មានភារកិច្ចត្រូវរាយការណ៍អំពីការអនុវត្តថវិកាជូនក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀងរាល់ខែ។ ថវិកាប្រចាំឆ្នាំទាំងនេះរាប់បញ្ចូលប្រភេទថវិកាផ្សេងៗ រួមមាន ប្រាក់បៀវត្សរ៍ និងចំណាយបុគ្គលិកផ្សេងទៀត (ជំពូក ៦៤) ទំនិញ និងសេវាកម្ម (ជំពូក ៦០, ៦១, ៦៣) ដែលត្រូវបានចែកជាចំណាយតាមកម្មវិធី និងចំណាយមិនតាមកម្មវិធី។ រៀងរាល់ឆ្នាំ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក៏ត្រូវបានធ្វើសវនកម្មផងដែរដោយស្ថាប័នផ្សេងៗ រួមមាន ក្រុមសវនកម្មផ្ទៃក្នុងនៃក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរ សវនកម្មជាតិ។ ដើម្បីបំពេញលក្ខខ័ណ្ឌធ្វើសវនកម្មរបស់ស្ថាប័នខាងលើ មន្ទីរអប់រំ យុវជន និងកីឡាខេត្តរក្សាទុកឯកសារថវិកាមួយចំនួន ដោយទទួលបានព័ត៌មានមួយចំនួនពីការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងសាលារៀន។

ការិយាល័យផែនការនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ផលិតជារៀងរាល់ឆ្នាំនូវស្ថិតិ និងអាំងឌីកាទ័រអប់រំសម្រាប់ខេត្តដែលបង្ហាញលម្អិតនូវការបំពេញមុខងារក្នុងវិស័យអប់រំនៅក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយ និងគោលដៅសម្រាប់ឆ្នាំបច្ចុប្បន្ន។ ស្ថិតិបែបនេះអាចផ្តល់ជូនតាមសំណើ ដែលរួមមានព័ត៌មានអំពីការចូលរៀនតាមថ្នាក់នីមួយៗ សិស្សប្រុសនិងសិស្សស្រី អត្រាត្រួតថ្នាក់ ចំនួនសាលារៀន គ្រូបង្រៀន និងសៀវភៅសិក្សា ។ល។ ព័ត៌មានទាំងនេះត្រូវបានចងក្រងដោយការិយាល័យអប់រំ យុវជន និងកីឡាខេត្ត ដោយផ្អែកលើព័ត៌មានដែលផ្តល់មកពីសាលារៀន និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក។ ជាធម្មតា ព័ត៌មានស្តីពីសៀវភៅសិក្សា

មានលក្ខណៈមិនច្បាស់ ដោយនាយកសាលាទំនងជាមិនបានរាយការណ៍អំពីការបាត់ ឬការខូចខាតនៃសៀវភៅទាំងនោះ ។

ជាធម្មតា ការិយាល័យផែនការនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក៏ទទួលបន្ទុកផងដែរលើការប្រមូល ***ព័ត៌មានស្ដីពីសកម្មភាពរបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល*** នៅក្នុងខេត្ត ។ ប៉ុន្តែ ដូចការកត់ត្រាបង្ហាញ ព័ត៌មានដោយឡែកនេះគឺមិនសូវមានឡើយ ។ មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បង្ហាញថា ទោះបីជាមានការខិតខំរបស់ពួកគេក្តី ក៏មានការចែករំលែកព័ត៌មានមិនច្បាស់ពីអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការនៅក្នុងវិស័យអប់រំ ។ ហេតុដូច្នេះ ប្រហែលជាមិនមានអ្នកណាម្នាក់អាចមើលឃើញទាំងស្រុងថាតើមូលនិធិចំនួនប៉ុន្មានត្រូវបានវិភាជន៍ឱ្យវិស័យអប់រំតាមរយៈគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាល ឬម្ចាស់ជំនួយនៅក្នុងខេត្តជាក់លាក់ណាមួយឡើយ ។

ផ្ទុយទៅវិញ ការិយាល័យហិរញ្ញវត្ថុនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត គឺទទួលបន្ទុកលើការរក្សាទុកឯកសារថវិកា និងរបាយការណ៍ទាំងអស់ ។ ដូចបានបង្ហាញខាងលើ ប្រាក់បៀវត្សរ៍ O&M ថវិកាតាមកម្មវិធី និងការផ្ទេរភោគផលផ្សេងៗក្នុងទម្រង់ដូចគ្នាត្រូវធ្វើពីថ្នាក់កណ្ដាល ឬពីម្ចាស់ជំនួយ/អង្គការមិនមែនរដ្ឋាភិបាល ទៅឱ្យថ្នាក់ខេត្ត ឬថ្នាក់ក្រោមផ្សេងទៀត ។ ការិយាល័យហិរញ្ញវត្ថុនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ទទួលបន្ទុករៀបចំថវិកាអប់រំខេត្ត ដែលត្រូវដាក់បញ្ចូលទៅក្នុងថវិកាក្រសួងអប់រំ យុវជន និងកីឡា និងត្រូវចរចាររវាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ***ផែនការថវិកា ឬសំណើ*** ត្រូវបានបញ្ចប់ និងដាក់ជូនទៅ ក្នុងខែសីហាជារៀងរាល់ឆ្នាំ ។ ក្រោយពេលទទួលការអនុម័តពីរដ្ឋសភា មន្ទីរអប់រំ យុវជន និងកីឡាខេត្តនីមួយៗនឹងមានថវិកាផ្ទាល់ខ្លួនដែលត្រូវអនុវត្ត ។ ក្រោមការត្រួតពិនិត្យរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តក្នុងនាមជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុ រតនាគារខេត្តក្នុងនាមជាគណនេយ្យករសាធារណៈ និងអភិបាលខេត្តក្នុងនាមជាប្រតិភូអនុញ្ញាតចំណាយ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត***រក្សាទុករបាយការណ៍សង្ខេបមួយស្ដីពីការប្រតិបត្តិថវិកាក្នុងមួយខែ*** ។ របាយការណ៍បែបនេះ បង្ហាញអត្រាប្រតិបត្តិប្រចាំខែ និងសរុបសម្រាប់គ្រប់ជំពូកថវិកាទាំងអស់ ។ ដូចបានលើកឡើងនៅក្នុងផ្នែក ៥.២ ខាងលើ ជំពូកថវិកាទាំងនេះរាប់បញ្ចូលតែថវិកាចរន្តប៉ុណ្ណោះ ពោលគឺមិនមានចំណាយមូលធនទេ ។ របាយការណ៍នេះត្រូវដាក់ជូនក្រសួងអប់រំ យុវជន និងកីឡារៀងរាល់ខែ ដូច្នេះទិន្នន័យអាចបូកសរុបចូលទៅក្នុងរបាយការណ៍អនុវត្តថវិកាប្រចាំខែរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។

បន្ថែមលើចំណុចខាងលើ មន្ទីរអប់រំ យុវជន និងកីឡាខេត្តក៏រក្សាទុកផងដែរនូវរបាយការណ៍ដោយឡែកសម្រាប់ប្រភេទថវិកានីមួយៗ ។ ចំពោះចំណាយប្រាក់បៀវត្សរ៍ (ជំពូក ៦៤) មន្ទីរអប់រំ យុវជន និងកីឡាខេត្ត រក្សាទុក ***តារាងស្ដីពីការបើកប្រាក់បៀវត្សរ៍ប្រចាំខែ*** ដែលផ្តល់ព័ត៌មានលម្អិត រួមទាំងឈ្មោះរបស់គ្រូ/ បុគ្គលិកសិក្សា ឋានៈរបស់ពួកគេ ប្រាក់បៀវត្សរ៍មូលដ្ឋាន ការឧបត្ថម្ភផ្សេងទៀត និងហត្ថលេខារបស់ពួកគេដែលបង្ហាញពីការទទួលប្រាក់ខែ ។ តារាងនេះដាក់បញ្ចូលគ្រប់បុគ្គលិកថ្នាក់ខេត្តទាំងអស់ និងត្រូវបានរៀបចំដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដោយផ្អែកលើព័ត៌មានដែលផ្ញើមកពីការិយាល័យអប់រំ យុវជន និងកីឡាស្រុក និង

សាលារៀន។ ប៉ុន្តែ គេគប្បីកត់សម្គាល់ថាឯកសារដោយឡែកត្រូវបានរក្សាទុកសម្រាប់ការបើកប្រាក់បៀវត្សរ៍ដែលបានធ្វើជូនគ្រូជាប់កិច្ចសន្យា និងការឧបត្ថម្ភតែមួយដងផ្សេងទៀតជូនបុគ្គលិក ដូចជាការចូលនិវត្តន៍ មរណភាព និងជំនួយពាក់ព័ន្ធផ្សេងទៀត។

សម្រាប់ការទិញទំនិញ និងសេវាកម្ម (ជំពូក ៦០, ៦១ និង ៦៣) មន្ទីរអប់រំ យុវជន និងកីឡាខេត្តរៀបចំឯកសារផ្សេងៗ។ ទីមួយ មន្ទីរអប់រំ យុវជន និងកីឡាខេត្តរៀបចំ ***កម្មវិធីទូទាត់រជ្ជទេយ្យបុរេប្រទាន*** ដែលត្រូវបានអនុម័តនៅដើមឆ្នាំ មុនដំណាច់ខែមករា យោងតាមការិយាល័យហិរញ្ញវត្ថុនៃមន្ទីរ អប់រំ យុវជន និងកីឡាខេត្ត។ រជ្ជទេយ្យបុរេប្រទានទាំងនេះត្រូវបានចំណាយភាគច្រើននៅថ្នាក់ខេត្ត ទោះបីជាមានរជ្ជទេយ្យបុរេប្រទានខ្លះត្រូវបានផ្ទេរទៅដល់ថ្នាក់ស្រុកក្តី។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត អាចមានរជ្ជទេយ្យបុរេប្រទានរហូតដល់ប្រាំបីដង ដែលចំនួនសរុបមិនអាចលើសពី ៣០% នៃថវិកាសរុបសម្រាប់ទំនិញ និងសេវាកម្ម។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចាំបាច់ត្រូវជម្រះរជ្ជទេយ្យបុរេប្រទាននីមួយៗមុនពេលដែល រជ្ជទេយ្យបុរេប្រទានបន្ទាប់អាចចេញបាន។ រាល់ឯកសារចំណាយទាំងអស់ចាំបាច់ត្រូវភ្ជាប់មកជាមួយ សម្រាប់ការជម្រះនេះ។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក៏រក្សាទុកផងដែរនូវ ***សៀវភៅបញ្ជីបេឡា*** ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំថ្ងៃ។ យ៉ាងហោចណាស់ ៧០% នៃទំនិញនិងសេវាកម្មដែលគេត្រូវការចាំបាច់ ត្រូវទិញតាមរយៈលទ្ធកម្មសាធារណៈ។ ជាថ្មីម្តងទៀត ដូចដែលត្រូវបានកំណត់ដោយស្ថាប័នធ្វើសវនកម្មផ្សេងៗ មន្ទីរអប់រំ យុវជន និងកីឡាខេត្តរក្សាទុករាល់ឯកសារគាំទ្រទាំងអស់សម្រាប់ប្រតិបត្តិការលទ្ធកម្មនីមួយៗ ដើម្បីរក្សាទុកព័ត៌មានស្តីពីតម្លៃលទ្ធកម្ម និងប្រការដែលថាតើកិច្ចដំណើរការនេះចំណាយពេលអស់ប៉ុន្មាន។ ប៉ុន្តែគេគប្បីកត់សម្គាល់ថា មន្ទីរអប់រំ យុវជន និងកីឡាខេត្តមិនមានចូលរួមក្នុងកិច្ចដំណើរការលទ្ធកម្មទេ ដូច្នេះមិនមានរក្សាទុកឯកសារស្តីអំពីថាតើអ្នកចុះកិច្ចសន្យាបានទទួលការទូទាត់នៅពេលណានិងតាមរបៀបណានោះទេ ក្រោយពេលប្រគល់សេវាកម្ម/ ទំនិញ។ ព័ត៌មានបែបនេះមានតែនៅរតនាគារខេត្តប៉ុណ្ណោះ។ គួរឱ្យសោកស្តាយ រតនាគារខេត្តនៅបន្តប្រើការកត់បញ្ជីទូទាត់ដោយដៃ ទោះបីជាមានការដាក់ឱ្យប្រើកំព្យូទ័រដើម្បីកត់ត្រាបញ្ជាទូទាត់ និងការទូទាត់ជាក់ស្តែងជូនអ្នកចុះកិច្ចសន្យាផ្សេងៗក្តី។ ម្យ៉ាងទៀត មានការលំបាកខ្លាំងក្នុងការទទួលបាននូវការអនុញ្ញាតិចំពោះការសុំព័ត៌មានពីរតនាគារ លុះត្រាតែមានលិខិតអនុញ្ញាតិមួយចេញពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[១៣]។

ដូចបានលើកឡើងខាងលើ ទំនិញនិងសេវាកម្មដែលបានទិញតាមរយៈរជ្ជទេយ្យបុរេប្រទានត្រូវបានប្រើភាគច្រើននៅថ្នាក់ខេត្ត ថ្វីបើយោងតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត មានទំនិញនិងសេវាកម្មខ្លះត្រូវបានផ្ទេរទៅដល់ការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងតិចតួចមែនទែនផ្ទេរទៅដល់សាលារៀន។ ទំនិញខ្លះប្រើបានយូរជាងមួយឆ្នាំ ដូច្នេះចាំបាច់ត្រូវដាក់ចូលក្នុងបញ្ជីសារពើភ័ណ្ឌ។ សម្រាប់គោលបំណងនេះ មន្ទីរអប់រំ យុវជន

[១៣] ព័ត៌មានអំពីផ្នែកនេះ គឺផ្អែកលើ PETS (ឆ្នាំ ២០០៤) និងការបញ្ជាក់ជាមួយមន្ត្រីហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៨។

និងកីឡាខេត្តនីមួយៗ រក្សាបញ្ជីសារពើភ័ណ្ឌមួយដែលបង្ហាញនូវអ្វីដែលបានទិញ និងអ្វីដែលត្រូវបានផ្ទេរ។ បញ្ជីនេះតាមពិតត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ។ ប៉ុន្តែគេមិនបានធ្វើដូចនេះទេ។

ការរៀបចំឯកសារបានល្អជាងគឺ ឯកសារថវិកាតាមកម្មវិធី។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងអង្គភាពថ្នាក់ក្រោមដែលពាក់ព័ន្ធ មានសិទ្ធិចំពោះថវិកាតាមកម្មវិធីមួយចំនួន (ដែលនៅក្នុងនោះ ថវិកាតាមកម្មវិធីចំនួន ១២ ត្រូវបានកំណត់)។ នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាស្រុកនីមួយៗ មជ្ឈមណ្ឌលគ្រប់គ្រងថវិកាមួយត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងមូលនិធិដោយឡែកនេះ។ ប៉ុន្តែ គេគប្បីកត់សម្គាល់ថា ថវិកាផ្នែកលើកម្មវិធីរាប់បញ្ចូលតែចំណាយប្រតិបត្តិការមិនមែនប្រាក់ខែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តី ក៏ថវិកាតាមកម្មវិធីតំណាងឱ្យមួយចំណែកធំនៃថវិកាចរន្តសរុបក្នុងកម្រិតប្រហែល ២០ ភាគរយ (ក្នុងឆ្នាំ២០០៧)។ ទាំងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និង ការិយាល័យអប់រំ យុវជន និងកីឡាស្រុក រក្សាទុករបាយការណ៍ប្រចាំខែស្តីពីការអនុវត្តថវិកាតាមកម្មវិធី។ មួយផ្នែកធំនៃថវិកាតាមកម្មវិធីសម្រាប់ថ្នាក់ក្រោមជាតិ គឺសំដៅផ្ទេរទៅឱ្យសាលារៀនអនុលោមតាមរូបមន្តមួយដែលត្រូវបានកំណត់ដោយប្រកាស។ សាលារៀននីមួយៗត្រូវបានផ្តល់ព័ត៌មានអំពីរូបមន្តនេះ ប៉ុន្តែមានសាលារៀន និងការិយាល័យអប់រំ យុវជន និងកីឡាស្រុកខ្លះបានបដិសេធថាមិនបានទទួលព័ត៌មាននេះទេ។ រូបមន្តនេះត្រូវបានប្រើនៅពេលបញ្ចេញប្រាក់ជូនសាលារៀននីមួយៗ ដែលនៅពេលនេះកំណត់ឱ្យត្រឹម៤ដង។ សាលារៀនចាំបាច់ត្រូវចាយប្រាក់ដែលបានទទួល យោងតាមការណែនាំដែលចេញដោយនាយកដ្ឋានកណ្តាលទាំងឡាយដែលទទួលបន្ទុកលើកម្មវិធីនីមួយៗ។ ជាថ្មីម្តងទៀត មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡាខេត្តបានអះអាងថាសាលារៀននីមួយៗត្រូវបានផ្តល់ព័ត៌មានអំពីការណែនាំនេះ ប៉ុន្តែសាលារៀនខ្លះបាននិយាយផ្ទុយពីនេះ។ សាលារៀនត្រូវបានតម្រូវឱ្យរៀបចំរបាយការណ៍ជម្រះចំណាយសម្រាប់ការបញ្ចេញប្រាក់លើកមុន មុនពេលដែលពួកគេអាចទទួលការបញ្ចេញប្រាក់បន្ទាប់។ ប៉ុន្តែ ការបំពេញតាមល័ក្ខខ័ណ្ឌរាយការណ៍ថ្មី គឺមានលក្ខណៈពិបាក ហើយចំណុចនេះហាក់បីដូចជាមូលហេតុចម្បងសម្រាប់ការយឺតយ៉ាវក្នុងការបញ្ចេញប្រាក់ និងអត្រាប្រតិបត្តិទាប ចាប់តាំងពីពេលដាក់ឱ្យអនុវត្តល័ក្ខខ័ណ្ឌនេះក្នុងឆ្នាំ២០០៦។

ព័ត៌មានស្តីពីថវិកាចំនួនតិចតួចជាងជាច្រើន ត្រូវបានរៀបចំនិងរក្សាទុកនៅថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាស្រុក។ ថ្វីបើថ្នាក់ស្រុកចែកចាយប្រាក់បៀវត្សរ៍ជូនគ្រូ និងថវិកាតាមកម្មវិធីសម្រាប់ការគ្រប់គ្រងសាលារៀនក្តី ក៏ឯកសារដែលការិយាល័យអប់រំ យុវជន និងកីឡាស្រុករៀបចំ គឺដើម្បីផ្ញើជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ចំពោះទំនិញនិងសេវាកម្ម ថវិកាពុំបានធ្លាក់ចុះទៅដល់ការិយាល័យអប់រំ យុវជន និងកីឡាស្រុកនោះទេ លើកលែងតែប្រាក់ឧបត្ថម្ភការធ្វើដំណើរសម្រាប់បុគ្គលិក ដែលតម្រូវឱ្យការិយាល័យអប់រំ យុវជន និងកីឡាស្រុករៀបចំព្រមទាំងដាក់ជូនរបាយការណ៍ចំណាយ និងបង្កាន់ដៃជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដែលទទួលបន្ទុកលើការជម្រះចំណាយជាមួយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត និងរតនាគារខេត្ត។ ថ្វីបើការិយាល័យអប់រំ យុវជន និងកីឡាស្រុក ត្រូវបានរំពឹងផងដែរថាអាចទទួលការផ្ទេរភោគផលខ្លះក្នុងទម្រង់ដូចគ្នា ពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ព្រមទាំងម្ចាស់ជំនួយ/អង្គការមិនមែនរដ្ឋាភិបាលផ្សេងៗក្តី ក៏បញ្ជីសារពើភ័ណ្ឌរបស់ពួកគេ មិនសូវបាន

រៀបចំឱ្យមាននោះទេ។ នៅថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ***ឯកសារដែលរក្សាបានល្អបង្អស់គឺថវិកាតាមកម្មវិធី*** ដែលត្រូវបានរៀបចំដោយមជ្ឈមណ្ឌលគ្រប់គ្រងថវិកាសម្រាប់ការបញ្ចេញប្រាក់នីមួយៗ។

គេគប្បីកត់សម្គាល់យ៉ាងប្រុងប្រយ័ត្នថាព័ត៌មានថវិកា និងឯកសារដែលបានលើកឡើងខាងលើ គឺស្តីពីថវិកាជាតិតែប៉ុណ្ណោះ។ ដោយសារតម្រូវឱ្យធ្វើសវនកម្ម គេឃើញច្បាស់ថាព័ត៌មានជាច្រើនត្រូវបានផលិតជារៀងរាល់ខែ និងរៀងរាល់ឆ្នាំ។ អ្នកវិភាគដែលចាប់អារម្មណ៍លើការវិភាជន៍ថវិកា ជាតិសម្រាប់វិស័យអប់រំនៅថ្នាក់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក អាចធ្វើការវិភាគផ្សេងៗច្រើនផ្អែកលើឃ្លាំងទិន្នន័យទាំងនេះ (ឧទាហរណ៍ ការវិភាជន៍ថវិកា ការប្រតិបត្តិនៅ ក្នុងឆ្នាំនិងឆ្លងឆ្នាំ ចំណែកមិនមែនប្រាក់ខែ/ប្រាក់ខែនៃចំណាយ ចំណាយតាមកម្មវិធីប្រៀបធៀបនឹងចំណាយមិនតាមកម្មវិធី ការចែកចាយមូលនិធិនៅគ្រប់កម្រិតនៃឋានានុក្រមតាមវិស័យ)។ ដោយសារលក្ខណៈមជ្ឈការបច្ចុប្បន្ននៃប្រព័ន្ធថវិកា បញ្ហាប្រឈមចម្បងគឺថា ព័ត៌មាននិងឯកសារទាំងអស់នេះ ដូចដែលបានបញ្ជាក់ច្បាស់ដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក អាចផ្សព្វផ្សាយបានតែនៅពេលណា ដែលមានការយល់ព្រមជាផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលខេត្តនិង/ឬស្ថាប័នថ្នាក់លើពាក់ព័ន្ធផ្សេងទៀតប៉ុណ្ណោះ។

រូបភាពផ្សេងមួយត្រូវបានរកឃើញ ទាក់ទិននឹងព័ត៌មានស្តីពីការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ ព័ត៌មានបែបនេះគឺមានលក្ខណៈបែកខ្ញែកគួរសម និងមានលក្ខណៈមិនពេញលេញច្រើន។ មន្ត្រីទាំងឡាយ ទាំងនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និង ការិយាល័យអប់រំ យុវជន និងកីឡាស្រុក បានត្អូញត្អែរអំពីប្រការដែលថា មានព័ត៌មានតិចតួចណាស់ដែលត្រូវបានចែករំលែកដោយអង្គការមិនមែន រដ្ឋាភិបាល និងម្ចាស់ជំនួយទាក់ទងនឹងសកម្មភាព និងហិរញ្ញវត្ថុគម្រោងរបស់ពួកគេ។ ***ឯកសារមួយស្តីពីការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានកំណត់ គឺបានមកពីការិយាល័យផែនការនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត***។ ឯកសារមួយឬពីរទំព័រនេះ គ្រាន់តែរាយឈ្មោះគម្រោង និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅក្នុងតំបន់របស់ពួកគេប៉ុណ្ណោះ។ ឯកសារមួយទៀត ដែលរក្សាទុកដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក៏ដូចជា ការិយាល័យអប់រំ យុវជន និងកីឡាស្រុក កត់ត្រាពីការងារសាងសង់ (ឧទាហរណ៍ សាលារៀន ថ្នាក់រៀន) ដែលត្រូវបានធ្វើហិរញ្ញប្បទានដោយម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ ប៉ុន្តែ ការកត់ត្រានេះគឺកត់ព័ត៌មានដែលមានអំពីប្រធានបទ។ ជារួមដូចដែលមន្ត្រីអប់រំមួយរូបបាននិយាយ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងអង្គភាពថ្នាក់ក្រោមផ្សេងទៀត មិនអាចទទួលបានព័ត៌មានអំពីសកម្មភាពរបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងតំបន់ពួកគេទេ កុំថាដល់ទៅព្យាយាមត្រួតពិនិត្យពួកគេ។

### ៦.៣ កម្រិតសាលារៀន និងសហគមន៍

សាលារៀនគឺជាកម្រិតទាបបំផុតនៅក្នុងខ្សែលំដាប់ផ្តល់សេវានៃវិស័យអប់រំ ។ សាលារៀនក៏ស្ថិតនៅជិតបំផុតដែរជាមួយអ្នកទទួលផល ពោលគឺសិស្ស និងគ្រួសាររបស់ពួកគេ។ សាលារៀនគឺជាកន្លែងដែលធាតុចូល (ឧទាហរណ៍ ថវិកា ទ្រព្យសម្បត្តិ កម្លាំងពលកម្ម) ត្រូវបានប្រែក្លាយទៅជាសេវាកម្ម។ ហេតុដូច្នេះ ការចូលរួមរបស់មាតាបិតាសិស្ស និងតំណាងរបស់ពួកគេនៅក្នុងប្រតិបត្តិការរបស់សាលារៀន គឺសំខាន់ណាស់ ។ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធសំខាន់ៗទទួលស្គាល់សារៈសំខាន់នៃការចូលរួមនេះ និងបាននឹងកំពុងខិតខំកែលម្អការចូលរួមនេះ ។ ជារួម សាលារៀនត្រូវទាក់ទងជាមួយអង្គភាពខាងក្រោមនៅថ្នាក់មូលដ្ឋានៈ

- គណៈកម្មាធិការទ្រទ្រង់សាលារៀន
- គណៈកម្មាធិការស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា ហើយសំខាន់បំផុត
- ក្រុមប្រឹក្សាឃុំ តាមរយៈគណៈកម្មការស្ត្រី និងកុមារ ។

គេគប្បីកត់សម្គាល់ថា គណៈកម្មាធិការទាំងនេះមិនមែនជាផ្នែកមួយនៃឋានានុក្រមរបស់ក្រសួងអប់រំ យុវជន និងកីឡានេះទេ ប៉ុន្តែគណៈកម្មាធិការទាំងនេះបង្កើតឡើងដើម្បីបំពេញតួនាទីដ៏សំខាន់នៅក្នុងការផ្តល់សេវាអប់រំ ។

រាជរដ្ឋាភិបាល និងម្ចាស់ជំនួយ បាននឹងកំពុងខិតខំលើកកម្ពស់សមត្ថភាព និងកិច្ចសហការនៅក្នុងចំណោមអង្គភាពថ្នាក់មូលដ្ឋានទាំងនេះ។ ឧទាហរណ៍ តាមរយៈគម្រោងសិទ្ធិកុមាររបស់ខ្លួន អង្គការUNICEF បាននឹងកំពុងជួយគាំទ្រអ្វីដែលគេហៅថា ជនបង្គោលស្ត្រី និងកុមារនៅក្នុងឃុំនីមួយៗ ដើម្បីបង្កើនការចូលរួមរបស់ក្រុមប្រឹក្សាឃុំនៅក្នុងវិស័យអប់រំ ។

ត្រឡប់មកប្រធានបទថវិកាវិញ សាលារៀនទទួលតែប្រាក់បៀវត្សរ៍សម្រាប់គ្រូរបស់ខ្លួន ថវិកាតាមកម្មវិធី និងការផ្ទេរភោគផលក្នុងទម្រង់ដូចគ្នាមួយចំនួនតូចពី ថ្នាក់កណ្តាល ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ ចំពោះប្រាក់បៀវត្សរ៍របស់គ្រូ សាលារៀនមិនមានរក្សាទុកនូវបញ្ជីឯកសារអ្វីទាំងអស់នៃការទូទាត់ដែលពាក់ព័ន្ធ។ តាមពិត គ្រូត្រូវចុះហត្ថលេខាលើបង្កាន់ដៃជាភស្តុតាងនៃការទទួលប្រាក់បៀវត្សរ៍របស់ខ្លួន ហើយបន្ទាប់មកបង្កាន់ដៃទាំងនេះនឹងត្រូវ ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងបន្ទាប់មក ផ្ញើជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ***ការវិភាជន៍ថវិកា និងចំណាយតែមួយគត់ដែលត្រូវបានកំណត់ឱ្យកត់ត្រាទុក និងរាយការណ៍ គឺថវិកាតាមកម្មវិធី ។*** ដោយអនុវត្តតាមកម្មវិធីសកម្មភាពជាអាទិភាព សាលារៀននីមួយៗចាំបាច់ត្រូវរៀបចំឯកសារគាំទ្រសម្រាប់ការបញ្ចេញប្រាក់នីមួយៗដែលខ្លួនទទួល ។ ប្រការនេះ គឺចាំបាច់សម្រាប់គោលបំណងគ្រប់គ្រង និងម្យ៉ាងទៀតដើម្បីធ្វើឱ្យសាលារៀនមានសិទ្ធិទទួលការបញ្ចេញប្រាក់បន្ទាប់ ។ សាលារៀននីមួយៗទទួលថវិកាតាមកម្មវិធី ដោយអនុវត្តតាមរូបមន្តជាក់លាក់មួយ និងចាំបាច់ត្រូវចាយប្រាក់តាមការណែនាំដោយស្ថាប័នថ្នាក់កណ្តាល ។

គេបានដឹងថាបច្ចុប្បន្នការចង់ដឹងរបស់មាតាបិតាសិស្សអំពីការបំពេញការងាររបស់សាលារៀន គឺនៅមានកម្រិតនៅឡើយ ដែលរារាំងពួកគេមិនឱ្យដាក់សម្ពាធចំពោះការសម្របសម្រួលនិងប្រសិទ្ធភាព ដើម្បីឱ្យមានការកែលម្អសាលារៀន។ ឧទាហរណ៍ ពុំសូវមានមាតាបិតាសិស្សចូលរួមព្រឹត្តិការណ៍សំខាន់ៗដែលធ្វើនៅសាលារៀន។ សាលារៀនពុំមានការទាក់ទងញឹកញាប់ជាមួយមាតាបិតាសិស្សនោះទេ។ ដើម្បីឱ្យអ្នកទទួលផលប្រយោជន៍ពិតប្រាកដចូលរួមនៅក្នុងការផ្ដល់សេវាអប់រំ ស្ថាប័នតំណាងជាពិសេសក្រុមប្រឹក្សាដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាជន ចាំបាច់ត្រូវពង្រឹងនិងសហការឱ្យបានកាន់តែជិតស្និទ្ធជាមួយសាលារៀន។ ប្រការនេះគឺសំខាន់នៅក្នុងបរិបទនៃកំណែទម្រង់ជឿនលឿនបែបវិមជ្ឈការ និងវិសហមជ្ឈការ ដែលនឹងត្រូវពិភាក្សានៅក្នុងផ្នែកខាងក្រោមនេះ។

## ៧. ការផ្លាស់ប្ដូរគោលនយោបាយនាពេលខាងមុខ

ដូចដែលបានលើកឡើងខាងលើ ការចេញផ្សាយព័ត៌មានថវិកានៅកម្ពុជាត្រូវការពេល ដើម្បីកែលម្អជាបន្តទៀត។ វាផ្អែកលើពីរចំណុចគឺ (១) ការធ្វើផែនការ និងកិច្ចដំណើរការធ្វើថវិកានៅក្នុងវិស័យអប់រំ និង (២) កំណែទម្រង់ទូលាយផ្សេងទៀតរបស់រាជរដ្ឋាភិបាល ជាពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការនិងសហវិមជ្ឈការ។ បទសម្ភាសន៍ជាមួយមន្ត្រីមកពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងដែលពាក់ព័ន្ធផ្សេងទៀត រួមមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃបានបង្ហាញថា ការផ្លាស់គោលនយោបាយខាងក្រោមនៅពេលខាងមុខ នឹងមានផលប៉ះពាល់ខ្លាំងលើការចេញផ្សាយព័ត៌មានស្ដីពីការវិភាជន៍ថវិកាជាតិ ក៏ដូចជាការគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលចំពោះវិស័យអប់រំផងដែរ:

### ៧.១ កំណែទម្រង់ក្នុងវិស័យអប់រំ

**ពង្រីកថវិកាតាមកម្មវិធី:** វិស័យអប់រំគឺជាវិស័យនាំមុខនៅក្នុងការសាកល្បងថវិកាតាមកម្មវិធី បន្ទាប់ពីបទពិសោធន៍របស់ក្រសួងជាមួយកម្មវិធីសកម្មភាពជាអាទិភាពពីឆ្នាំ២០០០ ដល់ ឆ្នាំ២០០៦។ ថវិកាតាមកម្មវិធីបច្ចុប្បន្ននេះត្រូវបានអនុវត្តទាំងនៅថ្នាក់កណ្ដាល និងថ្នាក់ខេត្ត។ បច្ចុប្បន្ន (ឆ្នាំ២០០៨) ថវិកានេះគ្របដណ្ដប់លើ ២០% នៃចំណាយវិស័យសរុប។ ប៉ុន្តែ គេរំពឹងថាចំណែកនេះនឹងកើនឡើងនៅក្នុងឆ្នាំខាងមុខនេះ នៅពេលដែលនីតិវិធីប្រតិបត្តិថវិកាតាមកម្មវិធីត្រូវបានសម្រួល ហើយសមត្ថភាពនៅថ្នាក់ក្រោមជាតិមានភាពប្រសើរឡើង[១៤]។ ចំពោះមុខបញ្ហាផ្សេងៗជាមួយការបញ្ចេញប្រាក់ចាប់តាំងពីពេលដាក់ឱ្យអនុវត្តថវិកានេះមក ក្រសួងអប់រំ យុវជន និងកីឡា មានគោលបំណងសម្រួលនីតិវិធីប្រតិបត្តិ និងនីតិវិធីរាយការណ៍ នៅក្នុងឆ្នាំសារពើពន្ធខាងមុខ (ពោលគឺចាប់ពីឆ្នាំ២០០៩ទៅ) ដើម្បីបង្កើនល្បឿនការបញ្ចេញប្រាក់ទាក់ទិននឹងថវិកាតាមកម្មវិធី។ អ្វីដែលពាក់ព័ន្ធទៅនឹងលទ្ធភាពទទួលព័ត៌មានស្ដីពីថវិកា គឺប្រការដែលថា ជាមួយថវិកាតាមកម្មវិធី ធនធានត្រូវផ្សារភ្ជាប់ជាមួយនឹង

---

[១៤] បទសម្ភាសន៍ជាមួយមន្ត្រីថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៨។

សេវាកម្ម។ និយាយតាមបែបម្យ៉ាងទៀត ថវិកាតាមកម្មវិធីប្ដូរការយកចិត្តទុកដាក់ពីអនុលោមភាព ទៅកាន់ការបំពេញការងារ។ ម្យ៉ាងទៀតដោយសារវាគឺជាគំនិតផ្ដួចផ្ដើមថ្មី ថវិកាតាមកម្មវិធីគឺជាកម្មវត្ថុនៃការគ្រប់គ្រងនិងការត្រួតពិនិត្យដ៏ជិតដល់ដែលនាំឱ្យមានការរាយការណ៍កាន់តែល្អ និងកាន់តែប្រយ័ត្នប្រយែង ព្រមទាំងការធ្វើបច្ចុប្បន្នកម្មថវិកាតាមកម្មវិធីប្រៀបធៀបនឹងជំពូកថវិកាផ្សេងទៀត។ ជាមួយយន្តការក្រុមការងារបច្ចេកទេសចម្រុះកាន់តែរឹងមាំ អង្គការមិនមែនរដ្ឋាភិបាលអាចរំពឹងនឹងទទួលបានព័ត៌មានបច្ចុប្បន្នកាន់តែទៀងទាត់អំពីការប្រតិបត្តិថវិកាតាមកម្មវិធីពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ហេតុដូច្នេះ នាពេលអនាគត គេរំពឹងថាថវិកាតាមកម្មវិធីនឹងកើនឡើង ទន្ទឹមនឹងនីតិវិធីចំណាយកាន់តែរលូន និងការរាយការណ៍កាន់តែប្រសើរឡើង។

**ផែនការដាក់ឱ្យអនុវត្តផែនការប្រតិបត្តិការប្រចាំឆ្នាំ (និងបន្ទាប់មកក្របខ័ណ្ឌចំណាយរយៈពេលមធ្យម):** យោងតាមក្រសួងអប់រំ យុវជន និងកីឡា ដោយសារការលំបាកដោយផ្នែកនៃការមានព័ត៌មានសរុបស្ដីពីជំនួយហិរញ្ញប្បទានពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល គេមានគម្រោងដាក់ឱ្យអនុវត្តនូវផែនការប្រតិបត្តិការប្រចាំឆ្នាំក្នុងឆ្នាំ២០០៩ សម្រាប់ការប្រើប្រាស់របស់គ្រប់នាយកដ្ឋាន និងអង្គភាពមូលដ្ឋានពាក់ព័ន្ធទាំងអស់។ ចំណុចនេះ គឺដូចគ្នានឹងអ្វីដែលវិស័យសុខាភិបាលបាននឹងកំពុងអនុវត្តចាប់តាំងពីឆ្នាំ២០០៥ មក។ ប្រសិនបើផែនការប្រតិបត្តិការប្រចាំឆ្នាំត្រូវបានអនុម័ត នោះគ្រប់នាយកដ្ឋានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងអង្គភាពថ្នាក់ក្រោមទាំងអស់ នឹងចាំបាច់ត្រូវរៀបចំផែនការរបស់ខ្លួនដោយផ្អែកលើសកម្មភាព គោលដៅ និងតម្រូវការហិរញ្ញប្បទានរបស់ខ្លួន (ពោលគឺពីក្រោមឡើងលើ) ខណៈដែលនាយកដ្ឋានកណ្ដាលពាក់ព័ន្ធ (ប្រហែលជានាយកដ្ឋានផែនការ និងនាយកដ្ឋានហិរញ្ញវត្ថុ) នឹងចាំបាច់ត្រូវកំណត់ធនធានដែលទទួលពីគ្រប់ប្រភពទាំងអស់ (ពីលើចុះក្រោម)។ បន្ទាប់មក កិច្ចដំណើរការទាំងពីរនេះ នឹងត្រូវបានផ្គូរផ្គងគ្នា។ ដោយធ្វើដូច្នេះ រូបភាពកាន់តែមានលក្ខណៈរួមមួយនៃហិរញ្ញប្បទានសម្រាប់វិស័យនេះនឹងលេចចេញឡើង។ ព័ត៌មានបែបនេះនឹងមានប្រយោជន៍ខ្លាំងសម្រាប់អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយដែលធ្វើការងារលើវិស័យអប់រំ ជាពិសេសប្រសិនបើវាអាចត្រូវបានផ្សព្វផ្សាយតាមរយៈយន្តការក្រុមការងារបច្ចេកទេសចម្រុះ។ ប៉ុន្តែតាមរយៈបទពិសោធន៍ពីវិស័យសុខាភិបាលកន្លងមក ផែនការប្រតិបត្តិការប្រចាំឆ្នាំតែឯងមុខជាមិនគ្រប់គ្រាន់ទេ។ សុខុដុមនីយកម្មកាន់តែច្រើនឡើងនៅក្នុងចំណោមម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាលនៅតែជាការចាំបាច់មួយ ដូច្នេះគេអាចពន្យល់បានយ៉ាងជាក់លាក់ចំពោះចំនួនគម្រោង ហើយគេក៏អាចកាត់បន្ថយនូវចំនួនគម្រោងរាយប៉ាយនានា។

**ការកែលម្អប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយ:** ទាក់ទិននឹងចំណុចខាងលើ ក្រសួងអប់រំ យុវជន និងកីឡា ព្យាយាមកែលម្អសមត្ថភាពរបស់មន្ត្រីសម្រាប់ការគ្រប់គ្រងមូលដ្ឋានទិន្នន័យដ៏សំខាន់ទាំងពីរៈ ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុជាមួយនាយកដ្ឋានហិរញ្ញវត្ថុ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយ

ជាមួយនាយកដ្ឋានផែនការ។ បទសម្ភាសន៍ជាមួយមន្ត្រីនាយកដ្ឋានផែនការ[១៥] បង្ហាញថាការិយាល័យសម្រប សម្រួលជំនួយកំពុងរីកចម្រើន និងទទួលបានបទពិសោធន៍នៅក្នុងរបៀបដែលពួកគេកសាងប្រព័ន្ធព័ត៌មាន គ្រប់គ្រងជំនួយ។ គេមិនដឹងច្បាស់ទេថា តើប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុនៃនាយកដ្ឋានហិរញ្ញវត្ថុនឹងអាច ដំណើរការពេញលេញបាននៅពេលណា ប៉ុន្តែយោងតាម HSSP ទិន្នន័យវិភាគដ៏សំខាន់មួយចំនួនបានដកស្រង់ចេញ រួចហើយពីប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុដែលមានស្រាប់។ លើសពីនេះទៀត ការពិភាក្សាថ្មីនៅក្នុងក្រុម ការងារបច្ចេកទេសអប់រំ (ដើមឆ្នាំ ២០០៩)បានស្នើថា មូលដ្ឋានទិន្នន័យហិរញ្ញប្បទានអភិវឌ្ឍផ្លូវការនៅក្រុម ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចដាក់បញ្ចូលមុខងារនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយនាពេលអនាគត។ ថ្វីបើពុំមាន សេចក្តីសម្រេចជាផ្លូវការអំពីចំណុចនេះក្តី ក៏វាបង្ហាញថាប្រព័ន្ធគ្រប់គ្រងធនធានហិរញ្ញវត្ថុនៅក្នុងវិស័យអប់រំអាច ប្រែប្រួលនៅក្នុងពេលអនាគតដ៏ខ្លី។

### ៧.២ កំណែទម្រង់ទូទាំងរាជរដ្ឋាភិបាល

**កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០០៨:** កំណែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈមានផលប៉ះពាល់ខ្លាំងបំផុតលើ លទ្ធភាពទទួលបានព័ត៌មានស្តីពីថវិកានៅក្នុងវិស័យអប់រំ និង ជារួម។ មុនពេលអនុម័តច្បាប់ហិរញ្ញវត្ថុឆ្នាំ២០០៨ ប្រព័ន្ធថវិកាអនុវត្តតាមច្បាប់ហិរញ្ញវត្ថុឆ្នាំ១៩៩៣ ដែលផ្តោត លើមជ្ឈការនៃអំណាច និងអនុលោមភាព។ យោងតាមច្បាប់ឆ្នាំ១៩៩៣នេះ ការធ្វើថវិកាគឺភាគច្រើនផ្តោតលើ ការគ្រប់គ្រងផ្ទៃក្នុងរបស់រាជរដ្ឋាភិបាល ដោយមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិបំពេញមុខងារ ជាតួអង្គកណ្តាល និងតួអង្គសំខាន់។ ច្បាប់ឆ្នាំ១៩៩៣ នេះមិនមានចែងពីតួនាទីរបស់សាធារណជននៅក្នុងកិច្ចការ ធ្វើថវិកាទេ។ ផ្ទុយទៅវិញ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងន័យជារួម និងច្បាប់ថវិកាឆ្នាំ២០០៨ ក្នុងន័យដោយឡែក ចែងពីការចូលរួមរបស់សាធារណជន និងសង្គមស៊ីវិល។ មាត្រា ៨៤ នៃច្បាប់ថវិកាឆ្នាំ២០០៨ ចែងដូចខាងក្រោម:

> ***"រាល់ការប្រតិបត្តិចំណូលនិងចំណាយទាំងអស់របស់រដ្ឋ ត្រូវគោរពតាមបទបញ្ញត្តិនិងគោលការណ៍ណែនាំ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រាល់ការកត់ត្រាបញ្ជីអំពីចំណូល និងចំណាយរបស់រដ្ឋបាល ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវតែគោរពតាមប្លង់គណនី និងមាតិកាថវិកា ហើយរបាយការណ៍ គណនេយ្យ និងហិរញ្ញវត្ថុទាំងអស់ត្រូវតែមានតម្លាភាព និងត្រូវផ្សព្វផ្សាយជាសាធារណៈ។"***

បញ្ញត្តិច្បាប់ថ្មីនេះបើកទូលាយនូវឱកាសសម្រាប់ឱ្យអង្គការសង្គមស៊ីវិលសុំចូលរួម និងបង្កើតវិធីសាស្ត្រអំពី របៀបចូលរួមដោយសុទ្ធចិត្តក្នុងកិច្ចការធ្វើថវិការបស់រដ្ឋ។

---

[១៥] ធ្វើនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

**កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - កែលម្អប្រព័ន្ធគណនេយ្យរបស់រាជរដ្ឋាភិបាលៈ** ទោះបីជាមានការដាក់ឱ្យអនុវត្តប្លង់គណនីថ្មី និងការដាក់បញ្ចូលគម្រោងឧបត្ថម្ភដោយម្ចាស់ជំនួយទៅក្នុងច្បាប់ថវិកាចាប់តាំងពីឆ្នាំ២០០៧មកក្តី ក៏ព័ត៌មាននិងការបង្ហាញពីថវិកានៅប្រទេសកម្ពុជានៅតែមានលក្ខណៈមជ្ឈការ (សម្រាប់ព័ត៌មានស្តីពីថវិកាជាតិ) និងរប៉ាត់រប៉ាយ (សម្រាប់ព័ត៌មានស្តីពីការជួយគាំទ្ររបស់ម្ចាស់ជំនួយ) និងភាគច្រើនមិនទាន់ពេលវេលា។ ជាក់ស្តែង កំណែទម្រង់សំដៅដើម្បី (១) អនុវត្តប្លង់គណនីចំពោះចំណាយ មូលធនដែលទទួលហិរញ្ញប្បទានក្នុងប្រទេស (មកដល់ពេលនេះ ប្លង់គណនីអនុវត្តតែចំពោះចំណាយចរន្តប៉ុណ្ណោះ) (២) ផ្តល់ព័ត៌មានមិនត្រឹមតែអំពីអ្វីដែលត្រូវបានបញ្ចេញប៉ុណ្ណោះទេ ប៉ុន្តែអំពីអ្វីដែលត្រូវបានចាយចេញពីគណនីនៃគម្រោងម្ចាស់ជំនួយផងដែរ (៣) កាត់បន្ថយការយឺតយ៉ាវនៅក្នុងការរៀបចំតារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ (៤) អនុវត្តយ៉ាងពេញលេញនូវប្រព័ន្ធកុំព្យូទ័រនៅក្នុងប្រព័ន្ធរតនាគារ (៥) ដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុនៅតាមអង្គភាពមួយចំនួនឱ្យបានមុនដំណាច់ឆ្នាំ២០១១ និង (៦) ដាក់ចេញចំណាត់ថ្នាក់ថវិកាកាន់តែលម្អិតគិតតាមខេត្តនិងស្ថាប័នវិមជ្ឈការ។[១៦] ជាមួយបទបញ្ញត្តិនៃច្បាប់ថវិកាឆ្នាំ២០០៨ កំណែទម្រង់ទាំងនេះនឹងផ្តល់ឱ្យអង្គការសង្គមស៊ីវិលនូវលទ្ធភាពកាន់តែច្រើនឡើងក្នុងការទទួលបានទិន្នន័យថវិកា កាន់តែពេញលេញ និងក្នុងលក្ខណៈបំបែកលម្អិត មិនត្រឹមតែនៅថ្នាក់កណ្តាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅថ្នាក់ក្រោមជាតិទៀតផង។

**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការៈ** កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺធ្វើនៅក្នុងរាជរដ្ឋាភិបាលទាំងមូល។ ជាមួយនឹងច្បាប់អង្គការ[១៧] ដែលត្រូវបានអនុម័តក្នុងខែឧសភា ឆ្នាំ២០០៨ និងត្រូវបានគាំទ្រដោយសម្តេចនាយករដ្ឋមន្ត្រី កំណែទម្រង់នេះត្រូវបានរំពឹងថានឹងលូតលាស់ទៅមុខ។ បច្ចុប្បន្ន កម្មវិធីជាតិមួយស្តីពីការអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់រយៈពេលដប់ឆ្នាំខាងមុខកំពុងត្រូវបានរៀបចំ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានផលប៉ះពាល់លើវិស័យផ្សេងៗ រួមទាំងវិស័យអប់រំ និងសុខាភិបាល។ កំណែទម្រង់នេះក៏សំដៅដាក់បញ្ចូលបន្ថែមទៀតនូវសមាសភាគប្រជាធិបតេយ្យ និងការចូលរួមទៅក្នុងរបៀបដែលសេវាសាធារណៈត្រូវបានផ្តល់។ ក្នុងខែឧសភា ឆ្នាំ២០០៩ ក្រុមប្រឹក្សាខេត្ត រាជធានី ស្រុក និងក្រុង នឹងត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រយោលដោយសមាជិកក្រុមប្រឹក្សាឃុំ។ ក្រុមប្រឹក្សាជាប់ឆ្នោតនីមួយៗនឹងមានរដ្ឋបាល និងថវិកាឯកភាពមួយ។ ថវិកាដែលពិចារណាផងដែរអំពីស្ថាប័នវិមជ្ឈការ ត្រូវបានកំណត់ឱ្យផ្សព្វផ្សាយជាសាធារណៈ យោងតាមច្បាប់អង្គការនិងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

---

[១៦] លីណើត (Lienert, I.) ហេលីស (J. Helis) និង អ្នកដទៃ (២០០៨)។ កម្ពុជាៈ កែលម្អគណនេយ្យរបស់រាជរដ្ឋាភិបាល។ ភ្នំពេញ, មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។

[១៧] រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ ២០០៨)។ "ច្បាប់ស្តីពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខ័ណ្ឌ"។

## ៨. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

របាយការណ៍នេះព្យាយាមវាយតម្លៃ ថាតើមានព័ត៌មានប៉ុន្មានស្តីពីហិរញ្ញប្បទានសម្រាប់វិស័យអប់រំត្រូវបានផ្សព្វផ្សាយ និងថាតើគេអាចរកបានព័ត៌មានដែលមានដោយងាយកម្រិតណា។ ឆ្លើយតបទៅនឹងសំណួរនេះ ផ្នែកនេះសន្និដ្ឋានថា ការចេញផ្សាយព័ត៌មាននិងលទ្ធភាពទទួលបានព័ត៌មាន មានភាពខុសគ្នារវាងព័ត៌មានស្តីពីការវិភាជន៍ថវិកាជាតិ និងព័ត៌មានស្តីពីការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ ព័ត៌មានជាច្រើនស្តីពីការវិភាជន៍ថវិកាជាតិកាលពីពេលកន្លងមក ត្រូវបានផលិត និងធ្វើមជ្ឈការ ថ្វីបើទិន្នន័យលម្អិតជាងនេះអាចរកបានតែនៅពេលណា មានការយល់ព្រមពីការិយាល័យថ្នាក់លើដែលជាល័ក្ខខ័ណ្ឌមួយ ហើយជួនកាលបង្ខំឱ្យអ្នកស្នើសុំព័ត៌មាន ត្រូវឆ្លងកាត់នីតិវិធីមួយដ៏វែង និងមិនអាចព្យាករទុកបាន។ ផ្ទុយទៅវិញ ព័ត៌មានស្តីពីការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល គឺមានតិចជាងនិងមានលក្ខណៈបែកខ្ញែកជាង ថ្វីបើអាចងាយរកបានជាងតាមការជាក់ស្តែង។

ការខិតខំដើម្បីកែលម្អស្ថានភាពនេះកំពុងដំណើរការ។ ជារួម កំណែទម្រង់ជាក់លាក់តាមវិស័យនៃការពង្រីកថវិកាតាមកម្មវិធីដែលអាចធ្វើបាន គ្រោងការណ៍ណែនាំអំពីផែនការប្រតិបត្តិការប្រចាំឆ្នាំ ក្នុងចំណោមផែនការផ្សេងទៀត និងកំណែទម្រង់ទូទាំងរាជរដ្ឋាភិបាល ក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ ផ្តល់នូវក្តីសង្ឃឹមលើឃ្លាំងព័ត៌មានស្តីពីហិរញ្ញប្បទានសម្រាប់វិស័យអប់រំ ដែលមានលក្ខណៈកាន់តែពេញលេញ និងងាយទទួលបាន។

ដើម្បីបំពេញបន្ថែមលើកំណែទម្រង់ដែលកំពុងដំណើរការ និងដោយជាបឋមសំដៅលើកកម្ពស់ការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងការធ្វើផែនការ ព្រមទាំងការគ្រប់គ្រងហិរញ្ញវត្ថុវិស័យអប់រំ អនុសាសន៍ខាងក្រោមត្រូវបានដាក់ជូនៈ

### ៨.១ សម្រាប់រយៈពេលខ្លី

*ការប្រើប្រាស់បន្ថែមទៀតនូវក្រុមការងារបច្ចេកទេសចម្រុះស្តីពីអប់រំ ក្នុងការស្នើសុំទិន្នន័យហិរញ្ញវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា*។ ដូចដែលបានលើកឡើងខាងលើ ការឯកភាពជាផ្លូវការគឺចាំបាច់តម្រូវអោយមានពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដើម្បីទទួលបានទិន្នន័យប្រចាំខែ និងប្រចាំឆ្នាំដែលរៀបចំដោយក្រសួង។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីអប់រំ បានបង្ហាញជោគជ័យរួចហើយក្នុងការទទួលបានការយល់ព្រមបែបនេះ និងព័ត៌មានដែលខ្លួនបានស្នើសុំ។ ដូច្នេះ ការទទួលបានព័ត៌មានតាមរយៈក្រុមការងារបច្ចេកទេសចម្រុះស្តីពីអប់រំអាចប្រែក្លាយឱ្យមានលក្ខណៈផ្លូវការនិងជាស្ថាប័ន ដែលជាផ្នែកមួយនៃរបៀបវារៈរបស់ក្រុមការងារបច្ចេកទេសចម្រុះស្តីពីអប់រំ។ ដោយសារអង្គការមិនមែនរដ្ឋាភិបាលមានតំណាងជាផ្លូវការនៅក្នុងក្រុមការងារបច្ចេកទេសចម្រុះស្តីពីអប់រំតាមរយៈភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ ពួកគេអាចទទួលផល

ប្រយោជន៍ដោយផ្ទាល់ពីអនុសាសន៍នេះ។ ពួកគេអាចវាយតម្លៃ និងតាមដានបានកាន់តែប្រសើរឡើងនូវស្ថានភាពហិរញ្ញវត្ថុនៅគ្រប់ជាន់ថ្នាក់នៃវិស័យអប់រំ។

*ការសម្របសម្រួលកាន់តែប្រសើរឡើងរវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា និង នៅក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល។* ភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ បានកំពុងសហការរួចជាស្រេចជាមួយក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងការធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំនូវគម្រោងរបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ ប៉ុន្តែ គេនៅឃើញមានលទ្ធភាពសម្រាប់ការកែលម្អ។ អន្តរកម្មនៅក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើវិស័យអប់រំ ជាពិសេស រវាងភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត គួគប្បីត្រូវកែលម្អផងដែរ និងប្រហែលជាគប្បីធ្វើឱ្យមានលក្ខណៈជាផ្លូវការ។

## ៨.២ សម្រាប់រយៈពេលមធ្យម និងវែង

ចំពោះមុខកិច្ចដំណើរការធ្វើផែនការ និងធ្វើថវិកាជាប្រចាំនៅក្នុងវិស័យអប់រំ ក៏ដូចជាកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈ អង្គការមិនមែនរដ្ឋាភិបាលដែលខិតខំទទួលព័ត៌មាន និងចូលរួមឱ្យបានកាន់តែប្រសើរឡើងនៅក្នុងការធ្វើផែនការ និងការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងវិស័យអប់រំ ចាំបាច់ត្រូវពិចារណាចំណុចខាងក្រោម៖

*ការទទួលព័ត៌មានបច្ចុប្បន្នភាពទៀងទាត់ស្តីអំពីកំណែទម្រង់សំខាន់ៗទាំងនៅក្នុងវិស័យអប់រំ និងអន្តរវិស័យ។* នៅក្នុងរយៈពេលបីទៅប្រាំឆ្នាំខាងមុខ អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធគប្បីធានាឱ្យបាននូវព័ត៌មានបច្ចុប្បន្នភាពទៀងទាត់ និងសមស្របស្តីពីវឌ្ឍនភាពនៅក្នុងការដាក់ឱ្យអនុវត្តផែនការប្រតិបត្តិការប្រចាំឆ្នាំ និងប្រសិនបើអាច ព័ត៌មានបច្ចុប្បន្នភាពអំពីក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ដើម្បីបណ្តុះវិធីថ្មី នៅក្នុងការធ្វើផែនការ និងការធ្វើថវិកា។ កិច្ចប្រឹងប្រែងទាំងនេះនឹងនាំទៅដល់ការផ្លាស់ប្តូរច្រើន នៅក្នុងរបៀបដែលទិន្នន័យថវិកាត្រូវបានបង្ហាញ និងផ្សព្វផ្សាយអោយមាន។ របៀបនៃការពង្រីក និងការផ្លាស់ប្តូរការគ្រប់គ្រងចំពោះថវិកាតាមកម្មវិធី គួគប្បីត្រូវតាមដានផងដែរ។ ទន្ទឹមនឹងនេះ សកម្មភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លើការកែលម្អគណនេយ្យសាធារណៈ គប្បីត្រូវតាមដានឱ្យបានទៀងទាត់។ ទំនាក់ទំនងទៀងទាត់ជាមួយម្ចាស់ជំនួយសំខាន់ៗលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងជាមួយសមាជិកនៃក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏នឹងមានប្រយោជន៍ផងដែរ។

*ការប្រើជាមូលដ្ឋាននូវបញ្ញត្តិនៃច្បាប់ថវិកាសាធារណៈឆ្នាំ២០០៨ ស្តីពីភាពចាំបាច់ត្រូវចែករំលែកព័ត៌មានស្តីពីថវិកាជូនសាធារណជន។* ច្បាប់ហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ចែងថាព័ត៌មានស្តីពីថវិកាចាំបាច់ត្រូវផ្សព្វផ្សាយជាសាធារណៈ។ ចំណុចនេះ គឺផ្ទុយទៅនឹងច្បាប់ឆ្នាំ១៩៩៣ ដែលមិនមានចែងអ្វីសោះអំពីតួនាទីរបស់សាធារណជននៅក្នុងកិច្ចការធ្វើថវិកា។ ថ្វីបើនៅមានកិច្ចការច្រើនដែលត្រូវធ្វើដើម្បីអនុវត្តច្បាប់ឆ្នាំ២០០៨ បទបញ្ញត្តិទូទៅ

នៅក្នុងច្បាប់នេះត្រូវតែត្រូវបានប្រើដោយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជាចំណុចចាប់ផ្ដើមមួយសម្រាប់ការទាមទារជាសាធារណៈ កាន់តែទូលាយឱ្យមានតម្លាភាពកាន់តែច្រើនឡើងនៅក្នុងវិស័យអប់រំ។ បញ្ហាតម្លាភាពគប្បីត្រូវបានលើកកាន់តែច្រើនឡើងនៅក្នុងវេទិការាជរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ដូចជាក្រុមការងារបច្ចេកទេសចម្រុះស្ដីពីអប់រំ និងកិច្ចប្រជុំពិគ្រោះយោបល់/វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា។

*ការយកចិត្តទុកដាក់កាន់តែច្រើនឡើងលើវិមជ្ឈការ និងវិសហមជ្ឈការ។* ជាមួយច្បាប់អង្គការ ដែលពាក់ព័ន្ធនិងមានស្រាប់ វិមជ្ឈការនិងវិសហមជ្ឈការ កំពុងដាក់ឱ្យអនុវត្តនូវកំណែទម្រង់ស៊ីជម្រៅ ប៉ុន្តែបន្តិចម្តងៗនៅក្នុងរបៀបដែលសេវានិងធនធានសាធារណៈត្រូវបានផ្តល់ឱ្យនិងវិភាជន៍។ ដូចបានលើកឡើងរួចហើយ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត រាជធានី ស្រុក និងក្រុង ត្រូវបានគ្រោងធ្វើក្នុងខែឧសភា ឆ្នាំ២០០៩។ ក្រុមប្រឹក្សាទាំងនេះ នឹងធ្វើជាតំណាងនៃគ្រប់នាយកដ្ឋានវិសហមជ្ឈការដែលពាក់ព័ន្ធទាំងអស់។ ថ្វីបើការផ្ទេរថវិកា និងមុខងារធ្វើថវិកាដែលពាក់ព័ន្ធ ទៅឱ្យថ្នាក់ក្រោមជាតិគឺមានលក្ខណៈបន្តិចម្តងៗក្តី ក៏ជាមួយកំណែទម្រង់នេះការធ្វើប្រព័ន្ធថវិកានឹងមានលក្ខណៈកាន់តែវិមជ្ឈការឡើង។ លើសពីនេះទៀត ច្បាប់អង្គការ និងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចែងថា ថវិកាក្រុមប្រឹក្សាចាំបាច់ត្រូវផ្សព្វផ្សាយជាសាធារណៈ។ ចំណុចនេះអាចមានន័យថា ពាក់ព័ន្ធនឹងលទ្ធភាពទទួលព័ត៌មានស្តីពីថវិកា អង្គការមិនមែនរដ្ឋាភិបាល និងសាធារណជនទូទៅ គ្រាន់តែទាក់ទងជាមួយក្រុមប្រឹក្សានីមួយៗប៉ុណ្ណោះ នៅពេលស្នើសុំព័ត៌មាន។ ជាការពិតណាស់ ប្រការនេះគឺងាយស្រួលច្រើនជាងប្រការ ដែលត្រូវដាក់សំណើផ្លូវការតាមឋានានុក្រមក្រសួងថ្នាក់កណ្តាល។ ជាមួយការមានក្រុមប្រឹក្សាថ្មីក្នុងមុខតំណែង គេក៏នឹងឃើញមានឱកាសកាន់តែច្រើនផងដែរចំពោះការតាមដានគម្រោងផ្សេងៗរបស់អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយក្រោមយន្តការចង្កោមតែមួយ ថ្វីបើវាអាចត្រូវការពេលវេលាក្តី។

ជាចុងក្រោយ ការធានា និងការជម្រុញការទទួលបានព័ត៌មានស្តីពីថវិកានៅក្នុងវិស័យអប់រំ (ក៏ដូចជានៅក្នុងវិស័យផ្សេងទៀតដែរ) មិនមែនគឺជាភារកិច្ចមួយដែលអាចសម្រេចបានដោយ ធ្វើការងារតែនៅក្នុងវិស័យនោះតែមួយទេ ឬដោយសកម្មភាពតែមួយដងឡើយ។ វាគឺជាភារកិច្ចអន្តរវិស័យ ដែលតម្រូវឱ្យមានការយល់ដឹងអំពីបញ្ហាអន្តរវិស័យ និងភាពជាដៃគូជាមួយស្ថាប័នផ្សេងៗក្រោមយន្តការមួយចំនួន។ យើងមិនចាំបាច់ "បង្កើតដំណើរការថ្មីឡើងវិញទេ" (ឧទាហរណ៍ បង្កើតយន្តការថ្មី)។ យើងអាចខិតខំពង្រឹងអ្វីដែលមានរួចជាស្រេចហើយ។ ដោយពិនិត្យមើលទៅអនាគតដ៏ខ្លី លទ្ធភាពទទួលបានកាន់តែច្រើនឡើង និងកាន់តែប្រសើរឡើងនូវព័ត៌មានស្តីពីថវិកានៅក្នុងវិស័យអប់រំ គឺមានកាន់តែច្រើនឡើង ដោយសារមានក្របខ័ណ្ឌគតិយុត្តិកាន់តែប្រសើរឡើង កំណែទម្រង់ដ៏រឹងមាំ និងការប្តេជ្ញាច្រើនពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។

## ឧបសម្ព័ន្ធទី ១: លំហូរព័ត៌មាន និងឯកសារដែលផលិតតាមកម្រិត និងស្ថាប័នផ្សេងៗគ្នា




កំណត់សម្គាល់:

→ លំហូរព័ត៌មាន

- - - - - - ខ្សែរចនាសម្ព័ន្ធស្ថាប័ន

——— ផលិតព័ត៌មាន/ឯកសារ

ប្រភព: អ្នកស្រាវជ្រាវ (២០០៩) យោងតាមកិច្ចសម្ភាសន៍ និងឯកសារពិគ្រោះ

## ឧបសម្ព័ន្ធទី ២: ឯកសារសំខាន់ៗផលិតនៅថ្នាក់ជាតិ និងការចេញផ្សាយឯកសារទាំងនេះ

| ស្ថាប័ន | ឯកសារ និង ពេលវេលានៃការបោះផ្សាយ | ព័ត៌មានពាក់ព័ន្ធ | ការចេញផ្សាយព័ត៌មាន |
|---|---|---|---|
| **១. ស្តីពីថវិកាជាតិ** | | | |
| រាជរដ្ឋាភិបាលកម្ពុជា | ច្បាប់ស្តីពីហិរញ្ញវត្ថុ: ប្រចាំឆ្នាំ ដែលអាចរកបាននៅខែធ្នូ នៃឆ្នាំ មុន | – សនិទានភាពគាំទ្រថវិកា<br>– បទប្បញ្ញត្តិថវិកាសំខាន់ៗ ដែលត្រូវបានចេញក្នុងឆ្នាំ<br>– ចំណូល និងចំណាយវិភាជន៍ ដែលត្រូវបានអនុម័ត (ចរន្ត, កម្មវិធី និងរាជធានី) និង គិតតាមថ្នាក់កណ្តាល ប្រៀបធៀបថ្នាក់ខេត្ត | – មាន មិនចាំបាច់ សំណើផ្លូវការ មិនចំណាយ ពេលច្រើន<br>– ទាក់ទងរដ្ឋសភា ព្រឹទ្ធសភា ឬក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | ច្បាប់ទូទាត់ថវិកា ការប្រតិបត្តិថវិកាប្រចាំឆ្នាំដែល ត្រូវបានឯកភាព: មិនត្រូវបានអនុម័តទៀងទាត់ អាចយឺតដល់ទៅពីរឆ្នាំ | – ការអនុវត្តថវិកាដែលត្រូវ បានអនុម័តសម្រាប់ រាល់ចំណូល និងចំណាយដែល បានឯកភាព | – មាន មិនចាំបាច់មាន សំណើផ្លូវការ មិនចំណាយពេលច្រើន<br>– ទាក់ទងរដ្ឋសភា ព្រឹទ្ធសភា ឬក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សៀវភៅលម្អិតបូនក្បាលស្តីពី ច្បាប់ថវិកាជាតិ ដែលរួមមាន:<br>– សៀវភៅទី ១: ច្បាប់ស្តីពី ថវិកាជាតិ<br>– សៀវភៅទី ២: ថវិកាសម្រាប់ ក្រសួងថ្នាក់កណ្តាល<br>– សៀវភៅទី ៣:ថវិកាសម្រាប់ មន្ទីរខេត្ត<br>– សៀវភៅទី ៤: ថវិកាសម្រាប់ សាលាខេត្ត<br>– ប្រចាំឆ្នាំ | – ព័ត៌មានទាំងអស់ដែលមាន នៅក្នុងច្បាប់ថវិកាជាតិ (ខាងលើ)<br>– ព័ត៌មានលម្អិតស្តីពីការ វិភាជន៍ថវិកាក្រសួងតាម មុខងារសេដ្ឋកិច្ច តាមខេត្ត និងព័ត៌មានលម្អិតអំពីខេត្ត នីមួយៗ | – មាន មិនចាំបាច់មាន សំណើផ្លូវការ មិនចំណាយពេលច្រើន ប៉ុន្តែអាចត្រូវទិញ<br>– ទាក់ទងនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ |
| | ក្របខ័ណ្ឌចំណាយរយៈពេល មធ្យម (MTEF) | | សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង |
| | ការអនុវត្តថវិការដ្ឋ (តារាងប្រតិបត្តិការហិរញ្ញវត្ថុ របស់រដ្ឋ) | – បង្ហាញការអនុវត្តថវិកា តាមខេត្ត តាមវិស័យ និង តាមគម្រោង | – មានជាសាធារណៈ មិន ចាំបាច់មានសំណើផ្លូវការ ប៉ុន្តែអាចត្រូវទិញពី |

| ស្ថាប័ន | ឯកសារ និង ពេលវេលានៃការបោះផ្សាយ | ព័ត៌មានពាក់ព័ន្ធ | ការចេញផ្សាយព័ត៌មាន |
|---|---|---|---|
| | ប្រចាំខែ និងប្រចាំឆ្នាំ អាចយឺតរហូតដល់ ជាងមួយខែ | | ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ |
| ក្រសួងផែនការ | ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រ ជាតិ NSDP ឆ្នាំ ២០០៦- ២០១០ | – បង្ហាញអាទិភាពតាមវិស័យ សូចនាករ និងតម្រូវការ ធនធានសម្រាប់រយៈពេល នោះ។ | – មានជាសាធារណៈពី ក្រសួងផែនការ |
| | កម្មវិធីវិនិយោគសាធារណៈ (PIP) ប្រចាំឆ្នាំ, ត្រូវចេញដំណាលគ្នា នឹងថវិកាជាតិ ប៉ុន្តែជាធម្មតា គឺមានភាពប្រែប្រួលទាក់ទិន នឹងការកំណត់ពេល | – ផែនការរំកិលរយៈពេល ៣ ឆ្នាំ នៃការវិនិយោគ សាធារណៈ ផ្ដល់ព័ត៌មាន លម្អិតអំពីគម្រោងតាមវិស័យ និងឆ្នាំ | – មានជាសាធារណៈ មិន ចាំបាច់មានសំណើផ្លូវការ ប៉ុន្តែ អាចត្រូវទិញ |
| ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានផែនការ និង ទំនាក់ទំនងអន្តរជាតិ | ស្ថិតិ និងអាំងឌីកាទ័រអប់រំ: ប្រចាំឆ្នាំ | – ស្ថិតិ និងអាំងឌីកាទ័រលម្អិត ស្ដីពីការងារអប់រំ និង ការធ្វើផែនការប្រចាំឆ្នាំ និង រយៈពេលមធ្យម | – មានជាសាធារណៈ ជាពិសេសចំពោះអង្គការ មិនមែនរដ្ឋាភិបាល (ឬ យ៉ាងហោចណាស់ងាយ រកបានជាងព័ត៌មាន ឬ ឯកសារស្ដីពីថវិកា) |
| | មូលដ្ឋានទិន្នន័យសម្រាប់ការ គ្រប់គ្រងវិស័យអប់រំ (EMIS) | – ព័ត៌មានលម្អិតសម្រាប់ផលិត ស្ថិតិនិងអាំងឌីកាទ័រអប់រំជាតិ | – រកបានតែប្រសិនបើមាន ការយល់ព្រមពីថ្នាក់លើ |
| | របាយការណ៍បូកសរុបការងារ ក្នុងវិស័យអប់រំ: ប្រចាំឆ្នាំ គប្បីរកបាននៅក្នុង អំឡុងខែមីនា នៃឆ្នាំបន្ទាប់ ប៉ុន្តែអាចយឺត | – សូចនាករប្រតិបត្ត តាមវិស័យរងអប់រំទាំងអស់ ការធ្វើថវិកា ការជួយគាំទ្ររបស់ ម្ចាស់ជំនួយ និងសកម្មភាព សម្រាប់ឆ្នាំខាងមុខ | – មានជាសាធារណៈ: ជាពិសេស សម្រាប់ អង្គការមិនមែន រដ្ឋាភិបាល |
| ក្រសួងអប់រំ យុវជន និង កីឡា, នាយកដ្ឋានហិរញ្ញវត្ថុ | ក្របខ័ណ្ឌចំណាយរយៈពេល មធ្យម (MTEF) | | សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង |
| | សៀវភៅថវិកាប្រចាំឆ្នាំ | – ការវិភាជន៍ថវិកាសម្រាប់ ថ្នាក់កណ្ដាល និងថ្នាក់ខេត្ត (តាមខេត្ត) និងតាម ថវិកាតាមកម្មវិធី និង ថវិកាមិនតាមកម្មវិធី | – ក៏មានផងដែរនៅក្នុង សៀវភៅទាំងបួនក្បាល ដែលចេញដោយ នាយកដ្ឋានថវិកានៃ ក្រសួងសេដ្ឋកិច្ច និង |

| ស្ថាប័ន | ឯកសារ និង ពេលវេលានៃការបោះផ្សាយ | ព័ត៌មានពាក់ព័ន្ធ | ការចេញផ្សាយព័ត៌មាន |
|---|---|---|---|
| | | | ហិរញ្ញវត្ថុ |
| | សៀវភៅតាមដានថវិកាការអនុវត្តថវិកាអប់រំ: ប្រចាំខែ និងប្រចាំឆ្នាំ | – ការប្រតិបត្តិថវិកាតាមជំពូកថវិកា | – រកបានតាមរយៈការយល់ព្រមជាផ្លូវការ ឬតាមរយៈក្រុមការងារបច្ចេកទេសចម្រុះស្តីពីអប់រំ |
| | សេចក្តីសង្ខេបអំពីការអនុវត្តថវិកាតាមកម្មវិធី: ប្រចាំខែ និងប្រចាំឆ្នាំ | – ការអនុវត្តថវិកាតាមកម្មវិធីប្រចាំឆ្នាំ គិតតាមខេត្តសម្រាប់បណ្តាឆ្នាំ និងខែទាំងនោះ (សម្រាប់របាយការណ៍ប្រចាំខែ) | – រកបានតាមរយៈការយល់ព្រមជាផ្លូវការឬតាមរយៈក្រុមការងារ បច្ចេកទេសចម្រុះស្តីពីអប់រំ |
| **២. ហិរញ្ញប្បទាន និងការជួយគាំទ្រពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល** | | | |
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | មូលដ្ឋានទិន្នន័យហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ: ពុំមានកំណត់ពេលវេលាទេ | – ការជួយគាំទ្រទាំងអស់របស់ម្ចាស់ជំនួយ តាមវិស័យ ឆ្នាំ និងខេត្ត និងការបញ្ចេញប្រាក់ទៅក្នុងគម្រោងនីមួយៗ (ប៉ុន្តែមិនមែនអ្វីដែលត្រូវចាយចេញពីគម្រោងទេ) | – មានជាសាធារណៈ មិនចាំបាច់មានសំណើផ្លូវការ<br>– ព័ត៌មានពីមូលដ្ឋានទិន្នន័យ ត្រូវបានប្រើដើម្បីរៀបចំរបាយការណ៍ស្តីពី ប្រសិទ្ធភាពជំនួយរៀងរាល់ឆ្នាំ |
| ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានផែនការ និងទំនាក់ទំនងអន្តរជាតិ | មូលដ្ឋានទិន្នន័យស្តីពីគម្រោងជំនួយក្នុងវិស័យអប់រំ: ប្រចាំឆ្នាំ ប៉ុន្តែ ជាធម្មតាគឺយឺត | – ព័ត៌មានលម្អិតស្តីពីគម្រោងនីមួយៗ រួមទាំងសកម្មភាព ប្រភពថវិកា ។ល។ (ប៉ុន្តែមិនមែនគម្រោងនិងថវិកាទាំងអស់សុទ្ធតែត្រូវបានដាក់បញ្ចូលនៅក្នុងមូលដ្ឋានទិន្នន័យនេះទេ) | – រកបានតែប្រសិនបើមានការយល់ព្រមពីថ្នាក់លើ<br>– ប៉ុន្តែ ព័ត៌មានពីមូលដ្ឋានទិន្នន័យត្រូវបានបោះពុម្ព និងផ្សព្វផ្សាយ ជាពិសេសចំពោះអង្គការមិនមែនរដ្ឋាភិបាល ។ |

## ឧបសម្ព័ន្ធទី ៣: ឯកសារថវិកាសំខាន់ៗដែលផលិតនៅថ្នាក់ក្រោមជាតិ និងការចេញផ្សាយឯកសារទាំងនេះ

### ថ្នាក់ខេត្ត ស្រុក និងសាលារៀន

| ប្រភេទព័ត៌មាន | ឯកសារ និង ពេលវេលានៃការបោះផ្សាយ | ព័ត៌មានពាក់ព័ន្ធ | ការចេញផ្សាយព័ត៌មាន |
|---|---|---|---|
| **មន្ទីរអប់រំ យុវជន និងកីឡាខេត្ត** | | | |
| **ការិយាល័យផែនការ: ការអនុវត្តលើការអប់រំ** | ស្ថិតិ និងអាំងឌីកាទ័រអប់រំ: ប្រចាំឆ្នាំ | សូចនាករអប់រំសំខាន់ៗ ទាំងអស់ រួមមាន អត្រាចូលរៀន អត្រាត្រួតថ្នាក់ សាលារៀន គ្រូ ។ល។ តាម ស្រុក និង សាលារៀន | – មានជាសាធារណៈ ប្រសិនបើ មានសំណើដាក់ជូនមន្ទីរអប់រំ យុវជន និង កីឡាខេត្ត<br>– របាយការណ៍នេះត្រូវបាន ផ្ញើ និងបូកសរុបនៅថ្នាក់ កណ្ដាល |
| **សេចក្ដីសង្ខេបថវិកា** | សៀវភៅតាមដានថវិកា: ប្រចាំខែ និងប្រចាំឆ្នាំ | ការអនុវត្តតាមខែ និងឆ្នាំ សម្រាប់គ្រប់ជំពូកថវិកា ទាំងអស់ | – ផ្ដល់ជូនបានតែប្រសិនបើ មានការយល់ព្រមជា ផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា ឬ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| **ថវិកាតាមកម្មវិធី** | របាយការណ៍ស្ដីពីការគ្រប់គ្រង និងការប្រើថវិកាតាមកម្មវិធី: ប្រចាំខែ និងប្រចាំឆ្នាំ | ការប្រតិបត្តិតាមគ្រប់ជំពូក ទាំងអស់នៃថវិកាតាមកម្មវិធី សម្រាប់ខេត្តទាំងមូល និង តាមស្រុក | – ផ្ដល់ជូនបានតែប្រសិនបើ មានការយល់ព្រមជា ផ្លូវការពីក្រសួងអប់រំ យុវជន និង កីឡា ឬ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>– ដាក់ជូនប្រចាំខែ និង ប្រចាំឆ្នាំជូនក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| | សេចក្ដីណែនាំអំពីការអនុវត្ត ថវិកាតាមកម្មវិធីឆ្នាំ ២០០៨ របស់នាយកដ្ឋានបឋមសិក្សា ចុះ ខែមីនា ឆ្នាំ២០០៨: ប្រចាំឆ្នាំ | ការណែនាំលម្អិតស្ដីពីមូលដ្ឋាន នៃការវិភាជន៍ ការអនុវត្ត និង ការរាយការណ៍ | – ផ្ដល់ជូនបានដល់សាលា រៀន និងស្រុក ប៉ុន្តែ សម្រាប់អង្គការមិនមែន រដ្ឋាភិបាលចាំបាច់ត្រូវមាន ការយល់ព្រម (ប៉ុន្តែ |

| ប្រភេទព័ត៌មាន | ឯកសារ និង ពេលវេលានៃការបោះផ្សាយ | ព័ត៌មានពាក់ព័ន្ធ | ការចេញផ្សាយព័ត៌មាន |
|---|---|---|---|
| | | | សាលារៀនខ្លះមិនបាន ឃើញការនែនាំនេះទេ) |
| **ទំនិញ និងសេវា (ថវិកាមិនតាមកម្មវិធី)** | តារាងលំអិតរជ្ជទេយ្យបុរេប្រទាន ប្រចាំឆ្នាំ | ផ្ដល់ព័ត៌មានលម្អិតអំពី រជ្ជទេយ្យបុរេប្រទាន និង ចំណាយរជ្ជទេយ្យបុរេប្រទាន | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្ដល់ជូនបាន ប្រសិនបើមានលិខិត យល់ព្រមពីស្ថាប័នថ្នាក់ កណ្ដាលពាក់ព័ន្ធ |
| | សៀវភៅបញ្ជីបេឡា: ប្រចាំថ្ងៃ ប្រចាំខែ ប្រចាំឆ្នាំ | បង្ហាញរជ្ជទេយ្យបុរេប្រទាន ការបញ្ចេញប្រាក់ និង ការជម្រះបញ្ជី | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្ដល់ជូនបាន ប្រសិនបើមានលិខិត យល់ព្រមពីស្ថាប័នថ្នាក់ កណ្ដាលដែលពាក់ព័ន្ធ |
| | សលាកប័ត្រតាមដានការ ប្រើប្រាស់ថវិកា ជំពូក ៦០, ៦១, ៦២, ៦៣<br>សលាកប័ត្រតាមដានការ ប្រើប្រាស់ ថវិកាជំពូក ៦០, ៦១, ៦២ និង ៦៣:<br>ប្រចាំខែ និងប្រចាំឆ្នាំ | អនុវត្តជំពូកថវិកា ៦០, ៦១, ៦២, ៦៣ | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្ដល់ជូនបាន ប្រសិនបើមានលិខិត យល់ព្រមពីស្ថាប័នថ្នាក់ កណ្ដាលដែលពាក់ព័ន្ធ |
| | បញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំ: ប្រចាំឆ្នាំ | សារពើភ័ណ្ឌទាំងអស់របស់ខេត្ត (ផ្ទេរចូល និងផ្ទេរចេញ) | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្ដល់ជូនបាន ប្រសិនបើមានលិខិត យល់ព្រមពីស្ថាប័នថ្នាក់ កណ្ដាលដែលពាក់ព័ន្ធ |
| **បៀវត្សរ៍** | តារាងទូទាត់បៀវត្សរ៍ប្រចាំខែ: ប្រចាំខែ | ព័ត៌មានលម្អិត តាមឈ្មោះរបស់ និយោជិតដែលទទួលបៀវត្សរ៍ មូលដ្ឋាន អត្ថប្រយោជន៍ផ្សេង ទៀត និងហត្ថលេខារបស់ ពួកគេនៅរាល់ពេលទទួលបាន បៀវត្សរ៍ | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្ដល់ជូនបាន ជាសាធារណៈ កាលណា មានការយល់ព្រមជា ផ្លូវការពីក្រសួងអប់រំ យុវជន និង កីឡា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ ស្ថាប័នថ្នាក់ កណ្ដាលផ្សេងទៀត |

| ប្រភេទព័ត៌មាន | ឯកសារ និង ពេលវេលានៃការបោះផ្សាយ | ព័ត៌មានពាក់ព័ន្ធ | ការចេញផ្សាយព័ត៌មាន |
|---|---|---|---|
| | តារាងទូទាត់ប្រាក់ឧត្ថម្ភម្តងគត់ និងវត្តជន និងតារាងផ្សេងទៀត: ប្រចាំឆ្នាំ | ព័ត៌មានលម្អិត តាមឈ្មោះរបស់ និយោជិត និង ចំនួន និង សមាសភាពនៃការជួយឧបត្ថម្ភ ដែលបានផ្តល់ | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្តល់ជូនបានជាសាធារណៈ ប្រសិនបើមានការយល់ព្រមជាផ្លូវការពី ក្រសួង អប់រំ យុវជន និងកីឡា និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬស្ថាប័នថ្នាក់កណ្តាលផ្សេងទៀត |
| | តារាងទូទាត់ប្រាក់បំណាច់ សម្រាប់គ្រូកិច្ចសន្យា: ប្រចាំឆ្នាំ | ព័ត៌មានលម្អិត តាមឈ្មោះ និង ការទូទាត់ប្រាក់ជូនបុគ្គលិកកិច្ចសន្យា | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្តល់ជូនបានជាសាធារណៈ ប្រសិនបើមានការយល់ព្រមជាផ្លូវការពី ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ ស្ថាប័នថ្នាក់កណ្តាលផ្សេងទៀត |
| **គម្រោងរបស់ម្ចាស់ជំនួយ/ អង្គការមិនមែនរដ្ឋាភិបាល** | ស្ថិតិ និងអាំងឌីកាទ័រអប់រំ: ប្រចាំឆ្នាំ | មានតែបញ្ជីមួយនៃគម្រោងនៃអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើប្រតិបត្តិការនៅក្នុងខេត្ត នៅក្នុងឆ្នាំកន្លងទៅ | – អាចផ្តល់ជូនបានជាសាធារណៈប្រសិនបើមានសំណើជូន មន្ទីរអប់រំ យុវជន និងកីឡាខេត្ត<br>– របាយការណ៍នេះត្រូវបានផ្ញើឱ្យ និងបូកសរុបនៅថ្នាក់កណ្តាល |
| **ការិយាល័យអប់រំ យុវជន និងកីឡាស្រុក** | | | |
| **ថវិកាតាមកម្មវិធី** | របាយការណ៍ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ថវិកាតាមកម្មវិធី: ប្រចាំខែ និងប្រចាំឆ្នាំ | ការប្រតិបត្តិ តាមជំពូកទាំងអស់នៃថវិកាតាមកម្មវិធី សម្រាប់ស្រុកទាំងមូល និង តាមសាលារៀន | – ផ្តល់ជូនបានតែប្រសិនបើមានការយល់ព្រមជាផ្លូវការពីក្រសួងអប់រំ យុវជន និង កីឡា ឬ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>– ដាក់ជូនប្រចាំខែ និង |

| ប្រភេទព័ត៌មាន | ឯកសារ និង ពេលវេលានៃការបោះផ្សាយ | ព័ត៌មានពាក់ព័ន្ធ | ការចេញផ្សាយព័ត៌មាន |
| --- | --- | --- | --- |
| | | | ប្រចាំឆ្នាំជូនក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| | សេចក្តីណែនាំអំពីការអនុវត្តថវិកាតាមកម្មវិធីឆ្នាំ២០០៨ របស់នាយកដ្ឋានបឋមសិក្សា ចុះខែមីនា ឆ្នាំ២០០៨: ប្រចាំឆ្នាំ | ការណែនាំលម្អិតអំពីមូលដ្ឋាននៃការវិភាជន៍ ការអនុវត្ត និង ការរាយការណ៍ (ប៉ុន្តែ ការិយាល័យអប់រំ យុវជន និង កីឡាស្រុកខ្លះ ត្អូញត្អែរថាពួកគេមិនបានទទួលការណែនាំនេះទេ) | – មានផ្តល់ជូនសាលារៀន និងស្រុក ប៉ុន្តែ សម្រាប់ អង្គការមិនមែនរដ្ឋាភិបាល ចាំបាច់ត្រូវមានការយល់ព្រមជាផ្លូវការ |
| **បញ្ជីសារពើភ័ណ្ឌ** | បញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំ: ប្រចាំឆ្នាំ | បញ្ជីសារពើភ័ណ្ឌទាំងអស់របស់ស្រុក (ផ្ទេរចូល និងផ្ទេរចេញ) | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្តល់ជូនបាន ប្រសិនបើមានលិខិតយល់ព្រមពីស្ថាប័នថ្នាក់កណ្តាលដែលពាក់ព័ន្ធ |
| **បៀវត្សរ៍** | តារាងទូទាត់បៀវត្សរ៍ប្រចាំខែ: ប្រចាំខែ | ព័ត៌មានលម្អិត តាមឈ្មោះរបស់និយោជិតដែលទទួលបៀវត្សរ៍មូលដ្ឋាន អត្ថប្រយោជន៍ផ្សេងទៀត និងហត្ថលេខារបស់ពួកគេនៅរាល់ពេលទទួលបៀវត្សរ៍ | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្សព្វផ្សាយជាសាធារណៈ ប្រសិនបើមានការយល់ព្រមជាផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬស្ថាប័នថ្នាក់កណ្តាលផ្សេងទៀត |
| | តារាងទូទាត់ប្រាក់ឧត្តម្ភម្តងគត់ និងវត្តជន និងតារាងផ្សេងទៀត: ប្រចាំឆ្នាំ | ព័ត៌មានលម្អិត តាមឈ្មោះរបស់និយោជិត និងចំនួន និង សមាសភាពនៃការជួយឧបត្ថម្ភដែលបានផ្តល់ | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្សព្វផ្សាយជាសាធារណៈ ប្រសិនបើមានការយល់ព្រមជាផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬស្ថាប័នថ្នាក់កណ្តាលផ្សេងទៀត |

| ប្រភេទព័ត៌មាន | ឯកសារ និង ពេលវេលានៃការបោះផ្សាយ | ព័ត៌មានពាក់ព័ន្ធ | ការចេញផ្សាយព័ត៌មាន |
|---|---|---|---|
| | តារាងប្រាក់បៀវត្សរ៍ សម្រាប់គ្រូកិច្ចសន្យាៈ ប្រចាំឆ្នាំ | ព័ត៌មានលម្អិតតាមឈ្មោះ និងការបើកប្រាក់បៀវត្សរ៍ជូនបុគ្គលិកកិច្ចសន្យា | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្សព្វផ្សាយជាសាធារណៈ ប្រសិនបើមានការយល់ព្រមជាផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬស្ថាប័នថ្នាក់កណ្ដាលផ្សេងទៀត |
| **ការប្រតិបត្តិក្នុងការអប់រំ** | ស្ថិតិ និងអាំងឌីកាទ័រអប់រំៈ ប្រចាំឆ្នាំ | - សូចនាករអប់រំទាំងអស់ សិស្ស គ្រូ ។ល។ តាមស្រុក និងសាលារៀន<br>- បញ្ជីមួយនៃគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងតំបន់ | – អាចផ្សព្វផ្សាយជាសាធារណៈប្រសិនបើមានសំណើជូន មន្ទីរអប់រំ យុវជន និងកីឡាខេត្ត<br>– របាយការណ៍ត្រូវបានផ្ញើ និងបូកសរុបនៅថ្នាក់ខេត្ត |
| **សាលារៀន** | | | |
| **ថវិកាតាមកម្មវិធី** | របាយការណ៍ស្ដីពីការគ្រប់គ្រង និងប្រើប្រាស់ថវិកាតាមកម្មវិធីៈ ប្រចាំខែ និងប្រចាំឆ្នាំ | ការប្រតិបត្តិ តាមជំពូកទាំងអស់នៃថវិកាតាមកម្មវិធី សម្រាប់ស្រុកទាំងមូល និងតាមសាលារៀន | – ផ្ដល់ជូនបាន ប្រសិនបើមានការយល់ព្រមជាផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ប៉ុន្តែ ឯកសារនេះអាចជូនឃុំ និងអាជ្ញាធរមូលដ្ឋានផ្សេងទៀតបាន)<br>– ដាក់ជូនប្រចាំខែ និងប្រចាំឆ្នាំជូនក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| | សេចក្ដីណែនាំអំពីការអនុវត្តថវិកាតាមកម្មវិធីឆ្នាំ២០០៨ របស់នាយកដ្ឋានបឋមសិក្សាៈ | ការណែនាំលម្អិតអំពីមូលដ្ឋាននៃការវិភាជន៍ ការអនុវត្ត និងការរាយការណ៍ | – មានជូនសាលារៀន និងស្រុក ប៉ុន្តែ សម្រាប់អង្គការមិនមែនរដ្ឋាភិបាល |

| ប្រភេទព័ត៌មាន | ឯកសារ និង ពេលវេលានៃការបោះផ្សាយ | ព័ត៌មានពាក់ព័ន្ធ | ការចេញផ្សាយព័ត៌មាន |
|---|---|---|---|
| | ប្រចាំឆ្នាំ | | ចាំបាច់ត្រូវមានការយល់ព្រម<br>– សាលារៀនអាចចែករំលែកឯកសារនេះជាមួយឃុំ និងអាជ្ញាធរមូលដ្ឋានផ្សេងទៀតបាន។ |
| **បញ្ជីសារពើភ័ណ្ឌ** | ការចុះបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំៈ ប្រចាំឆ្នាំ | បញ្ជីសារពើភ័ណ្ឌទាំងអស់របស់សាលារៀន (ផ្ទេរចូល និង ផ្ទេរចេញ) | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្ដល់ជូនបាន ប្រសិនបើមានលិខិតយល់ព្រមពីស្ថាប័នថ្នាក់កណ្ដាលដែលពាក់ព័ន្ធ |
| **បៀវត្សរ៍** | តារាងទូទាត់បៀវត្សរ៍ប្រចាំខែៈ ប្រចាំខែ | ព័ត៌មានលម្អិត តាមឈ្មោះរបស់និយោជិតដែលទទួលបៀវត្សរ៍មូលដ្ឋាន អត្ថប្រយោជន៍ផ្សេងទៀត និង ហត្ថលេខារបស់ពួកគេនៅរាល់ពេលទទួលបៀវត្សរ៍ | – សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែអាចផ្ដល់ជូនបាន ប្រសិនបើមានការយល់ព្រមជាផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬស្ថាប័នថ្នាក់កណ្ដាលផ្សេងទៀត |
| **ការប្រតិបត្តិក្នុងការអប់រំ** | ស្ថិតិ និងអាំងឌីកាទ័រអប់រំបីដងក្នុងមួយឆ្នាំៈ ខែវិច្ឆិកា ខែមីនា និងខែកក្កដា បូកនឹងរបាយការណ៍ការងារប្រចាំឆ្នាំ | – សូចនាករអប់រំសំខាន់ៗទាំងអស់ សិស្ស គ្រូ។ល។ តាមស្រុក និងសាលារៀន<br>– បញ្ជីមួយនៃគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងតំបន់ (ថ្វីបើគុណភាពនៃព័ត៌មានអាចខុសគ្នាច្រើនពីតំបន់មួយទៅតំបន់មួយ) | – អាចផ្ដល់ជូនជាសាធារណៈ ប្រសិនបើមានសំណើជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្ត<br>– របាយការណ៍ត្រូវបានផ្ញើ និងបូកសរុបនៅថ្នាក់ខេត្ត |

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

ការិយាល័យ: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ ទួលទំពូង ១
ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ-៣
ទូរស័ព្ទលេខ: ០២៣ ២១៤ ៤២៩
ទូរសារលេខ: ០២៣ ៩៩៤ ០៦៣
អ៊ីម៉ែល: ngoforum@ngoforum.org.kh
គេហទំព័រ: www.ngoforum.org.kh